ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ ធនាគារស្ថាបនា ភីអិលស៊ី

# SATHAPANA BANK CREDIT RISK MANAGEMENT

## ជំនាញ ហិរញ្ញវត្ថុ និងធនាគារ

រាជធានីភ្នំពេញ-ឆ្នាំ២០២៤

PHNOM PENH-2024

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ ធនាគារស្ថាបនា ភីអិលស៊ី

# SATHAPANA BANK CREDIT RISK MANAGEMENT

សាស្ត្រាចារ្យណែនាំ៖ ត្រុង សាវរី

ជំនាញ ហិរញ្ញវត្ថុ និងធនាគារ

រាជធានីភ្នំពេញ-ឆ្នាំ២០២៤

PHNOM PENH-2024

# មាតិកា

ទំព័រ

អារម្ភកថា ................................................................ i
រចនាសម្ព័ន្ធ................................................................ ii
សេចក្តីថ្លែងអំណរគុណ ................................................................ iii
អំណះអំណាង ................................................................ vi
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ................................................................ v

**ជំពូកទី១**
**សេចក្តីផ្តើម**

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ................................................................ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ................................................................ ១
១.៣ គោលបំណងនៃការស្រាវជ្រាវ................................................................ ១
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ................................................................២
    ១.៤.១ ទំហំដែនកំណត់ ................................................................២
    ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ................................................................២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ................................................................២
    ១.៥.១ ការប្រមូលទិន្នន័យបន្ទាប់ ................................................................២
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ................................................................២
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ................................................................៣

**ជំពូកទី២**
**ការគ្រប់គ្រងហានិភ័យឥណទានរបស់ធនាគារ**

២.១ លក្ខណៈទូទៅនៃការគ្រប់គ្រងហានិភ័យឥណទានរបស់ធនាគារ................................................................ ៤
    ២.១.១ និយមន័យធនាគារ................................................................ ៤
    ២.១.២ ប្រវត្តិរបស់ធនាគារ................................................................ ៤
    ២.១.៣ ទ្រឹស្តីពាក់ព័ន្ធនៃធនាគារ ................................................................ ៥
២.២ នីតិវិធីនៃការផ្តល់ឥណទានរបស់ធនាគារ................................................................ ៦
    ២.២.១ និយមន័យនីតិ ................................................................ ៦
    ២.២.២ ប្រវត្តិនៃនីតិ................................................................ ៦
    ២.២.៣ ទ្រឹស្តីពាក់ព័ន្ធនៃនីតិ................................................................៧
២.៣ កត្តាដែលបណ្តាលឱ្យកើតមានហានិភ័យឥណទាន ................................................................ ៨
    ២.៣.១ និយមន័យនៃពាក្យឥណទាន ................................................................ ៨

២.៣.២ ប្រវត្តិនៃឥណទាន ........ ៨
២.៣.៣ ទ្រឹស្តីពាក់ព័ន្ធនៃឥណទាន ........ ៩
២.៤ មធ្យោបាយនៃការគ្រប់គ្រងហានិភ័យឥណទាន ........ ១០
២.៤.១ និយមន័យនៃពាក្យគ្រប់គ្រង ........ ១០
២.៤.២ ប្រវត្តិនៃការគ្រប់គ្រង ........ ១១
២.៤.៣ ទ្រឹស្តីពាក់ព័ន្ធនៃការគ្រប់គ្រង ........ ១២

**ជំពូកទី៣**

**ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារស្ថាបនា ភីអិលស៊ី**

៣.១ ស្ថានភាពទូទៅនៃធនាគារស្ថាបនា ........ ១៣
៣.១.១ ប្រវត្តិរបស់ធនាគារស្ថាបនា ........ ១៣
៣.១.២ ចក្ខុវិស័យ បេសកម្ម គុណតម្លៃរបស់ធនាគារស្ថាបនា ........ ១៥
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ចរបស់ធនាគារស្ថាបនា ........ ១៦
៣.២ នីតិវិធីនៃការផ្តល់ឥណទានរបស់ធនាគារស្ថាបនា ........ ២៤
៣.២.១ ដំណាក់កាលទី១៖ការដាក់ពាក្យស្នើសុំខ្ចីប្រាក់ ........ ២៤
៣.២.២ ដំណាក់កាលទី២៖ការសិក្សាពីលទ្ធភាពរបស់អតិថិជន ........ ២៥
៣.២.៣ ដំណាក់កាលទី៣៖ការរៀបចំឯកសារខ្ចីប្រាក់ ........ ២៦
៣.២.៤ ដំណាក់កាលទី៤៖ការអនុម័តឥណទាន ........ ២៧
៣.២.៥ ដំណាក់កាលទី៥៖ការរៀបចំកិច្ចសន្យា ........ ២៧
៣.២.៦ ដំណាក់កាលទី៦៖ការរៀបចំបញ្ចូលទិន្ន័យ ........ ២៨
៣.២.៧ ដំណាក់កាលទី៧៖ការបញ្ចេញឥណទាន ........ ២៨
៣.២.៨ ដំណាក់កាលទី៨៖ការតាមដានប្រាក់សំណងនិងការប្រមូលប្រាក់សំណង ........ ២៩
៣.២.៩ ដំណាក់កាលទី៩៖ការចុះដោះស្រាយបញ្ហាខាងសងប្រាក់ ........ ២៩
៣.៣ កត្តាដែលបណ្តាលឱ្យកើតមានហានិភ័យឥណទាន ........ ៣០
៣.៣.១ កត្តាដែលបណ្តាលមកពីអតិថិជន ........ ៣០
៣.៣.២ កត្តាដែលបណ្តាលមកពីធនាគារ ........ ៣០
៣.៣.៣ កត្តាដែលបណ្តាលមកពីប្រធានសក្តិ ........ ៣០
៣.៤ មធ្យោបាយគ្រប់គ្រងហានិភ័យឥណទានឱ្យមានប្រសិទ្ធភាព ........ ៣០
៣.៤.១ មធ្យោបាយគ្រប់គ្រងហានិភ័យ និងការទប់ស្កាត់ ចំពោះអតិថិជន ........ ៣០
៣.៤.២ មធ្យោបាយគ្រប់គ្រងហានិភ័យ និងទប់ស្កាត់ ចំពោះធនាគារ ........ ៣១

**ជំពូកទី៤**

**ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ**

៤.១ ការវិភាគលើចំណុចខ្លាំង ........ ៣២
៤.២ ការវិភាគលើចំណុចខ្សោយ ........ ៣៣

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ........................................ ៣៤
៥.២ ការផ្តល់អនុសាសន៍ ........................................ ៣៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១**
**ប្រធានបទ៖ ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារស្ថាបនា ភីអិលស៊ី**

| | |
|---|---|
| គណៈកម្មការវាយតម្លៃទី១ | សាស្ត្រាចារ្យណែនាំ |
| បេក្ខបណ្ឌិត ស្រេង ផល្លា | ត្រុង សាវរី |
| គណៈកម្មការវាយតម្លៃទី៣ | គណៈកម្មការវាយតម្លៃទី២ |
| បេក្ខបណ្ឌិត យ៉ាក វុទ្ធី | បេក្ខបណ្ឌិត មាស សំណាង |
| ប្រធានគណៈកម្មការវាយតម្លៃនិងជាប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ | គណៈកម្មការវាយតម្លៃទី៤ |
| បណ្ឌិត សេង សំអឿន | បេក្ខបណ្ឌិត យ៉ែម សុខហៀក |
| **នាយកវិទ្យាស្ថាន** | នាយិការងអចិន្ត្រៃយ៍ |
| **បណ្ឌិត ហេង វ៉ាន់ដា** | បណ្ឌិត ហ៊ូ គុជគន្ធលីនណា |

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញហិរញ្ញវត្ថុ និងធនាគារ នៅវិទ្យាស្ថាន វ៉ាន់ដា អស់រយៈពេល៤ឆ្នាំសិក្សារួចមកក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនពាក់ព័ន្ធនឹងមុខវិជ្ជាហិរញ្ញវត្ថុនិងធនាគារជាពិសេស ក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញហិរញ្ញវត្ថុ និងធនាគារ គឺជាជំនាញមួយមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការធនាគារដូចគ្នា។ ដោយឡែក ដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ វិទ្យាស្ថាន វ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារហិរញ្ញវត្ថុ និងធនាគារ តាមរយៈកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្តការងារធនាគារ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារធនាគារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំបានសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី **«ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារស្ថាបនា ភីអិលស៊ី »** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការផ្តល់ឥណទានរបស់ធនាគារ។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



**ឡាត់ ចាន់ថា**

ID.B21/1394



**រីន រ៉ានី**

ID.B21/1349



**សួន សោភា**

ID.B21/2541



**ឆៃ ស្រី**

ID.B21/3126

# **សេចក្តីថ្លែងអំណរគុណ**

ក្រុមយើងខ្ញុំជានិស្សិតនៃវិទ្យាស្ថាន វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១ ជំនាញហិរញ្ញវត្ថុ និងធនាគារ

**សូមសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** នាយកនៃវិទ្យាស្ថាន វ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះសាស្ត្រាចារ្យ **ត្រុង សាវរី** ជាសាស្ត្រាចារ្យណែនាំ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃវិទ្យាស្ថានវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អំណរអំណាច**

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញហិរញ្ញវត្ថុ និងធនាគារ នៃវិទ្យាស្ថាន វ៉ាន់ដា ជំនាន់ទី២១៖

សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ «**ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារស្ថាបនា ភីអិលស៊ី**» នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ. .............. ខែ.......... ឆ្នាំ..... ...... ព.ស.២៥៦....

ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២....

**ហត្ថលេខាតំណាងក្រុម**

# សេចក្ដីសង្ខេបនៃការស្រាវជ្រាវ

ក្រោយពីបានបញ្ចប់ ការសិក្សាស្រាវជ្រាវអំពីប្រធានបទ ការគ្រប់គ្រង់ហានិភ័យក្នុងការផ្ដល់ឥណទាន របស់ធនាគារស្ថាបនា ភីអិលស៊ី ដែលបានឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្ដែងរបស់ធនាគារស្ថាបនា ភីអិលស៊ី។ ដើម្បីប្រៀបធៀបនូវទ្រឹស្ដីដែលបានសិក្សារួចជាមួយនឹងការអនុវត្តជាក់ស្ដែងកន្លងមក ការសិក្សាស្រាវជ្រាវនេះ បានធ្វើឡើងតាមរយៈឯកសារផ្សេងៗដែលមាននៅក្នុងអ៊ីនធឺណែតនិងឯកសារមួយចំនួនដែលបានស្រាវជ្រាវពីបណ្ណាល័យ។

នៅក្នុងជំពូកនីមួយៗ បានសិក្សាលើចំណុចដែលមានភាពប្រទាក់គ្នា ពីមួយជំពូកទៅមួយជំពូក។ ការសិក្សា និងធ្វើការបកស្រាយនូវរាល់ជំពូកសុទ្ធតែបានបង្ហាញពីខ្លឹមសារសំខាន់ៗ ដែលជំពូកទីមួយបាននិយាយផ្ដោតទៅលើ លំនាំ ចំណោទ បញ្ហា គោលបំណង ដែនកំណត់ និងវិសាលភាពនៃការគ្រប់គ្រង។ ចំណែកជំពូកទី២ បានបង្ហាញពីប្រវត្តិ ទ្រឹស្ដី និងនិយមន័យសំខាន់ៗដែលទាក់ទងនឹងប្រធានបទនៃការស្រាវជ្រាវ។ ចំពោះជំពូកទី៣ ពិតជាមានសារៈសំខាន់ណាស់គឺ ការផ្ដល់នូវការបកស្រាយទាំងមូលរបស់ប្រធានបទបានយ៉ាងលម្អិតជាងរាល់ជំពូកទាំងអស់ដោយបានបកស្រាយនូវរាល់សំណួរដែលបានចោទសួរក្នុងចំណោទបញ្ហា មិនតែប៉ុណ្ណោះក៏បានបង្ហាញពីប្រវត្តិដំណើរការនៃការគ្រប់គ្រងហានិភ័យឥណទាន និងសារៈសំខាន់នៃភាពជោគជ័យរបស់ធនាគារស្ថាបនាផងដែរ។ ក្នុងជំពូកទី៤ បានសិក្សាទៅលើចំណុចខ្លាំងនិងចំណុចខ្សោយរបស់ធនាគារ។សម្រាប់ជំពូកបញ្ចប់ក៏បានសិក្សាទៅលើសេចក្ដីសន្និដ្ឋាននិងការផ្ដល់អនុសាសន៍ដើម្បីជួយកែលម្អចំពោះចំណុចខ្សោយរបស់ធនាគារផងដែរ។

បន្ទាប់ពីការសិក្សាស្រាវជ្រាវនេះយើងអាចសន្និដ្ឋានបានថា ការគ្រប់គ្រង់ហានិភ័យក្នុងការផ្ដល់ឥណទានរបស់ធនាគារស្ថាបនា ភីអិលស៊ី ពិតជាមានលក្ខណៈល្អប្រសើរបើប្រៀបធៀបទៅនឹងដៃគូប្រកួតប្រជែង ព្រោះធនាគារមានគោលការណ៍ច្បាស់ មានតម្លាភាព សុក្រឹត និងមានភាពទាក់ទាញដល់អតិថិជនដែលបានខ្ចីប្រាក់។

ដោយផ្អែកលើភាពសុក្រឹត និងប៉ិនប្រសព្វក្នុងការស្វែងរកគំនិតថ្មីៗ ដើម្បីទប់ស្កាត់ហានិភ័យដែលកើតមានឡើងនៅក្នុងធនាគារ រួមទាំងអាចទាក់ទាញអតិថិជនឱ្យមកប្រើប្រាស់សេវាកម្មរបស់ធនាគារស្ថាបនាដោយមានទំនុកចិត្តនិងសុវត្ថិភាពខ្ពស់។

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

នៅពេលបច្ចុប្បន្ននេះមានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុជាច្រើន កំពុងបម្រើសេវាកម្មដល់អតិថិជន ហើយអតិថិជនមុននឹងធ្វើការសម្រេចចិត្តប្រើប្រាស់សេវាកម្ម របស់ស្ថាប័នណាមួយ គឺពួកគាត់សុទ្ធតែបាន ត្រិះរិះ យ៉ាងល្អិតល្អន់ពីការបម្រើសេវាកម្ម និងអត្ថប្រយោជន៍ផ្សេងៗទៀតដែលគាត់នឹងទទួលបានពីស្ថាប័ន នោះ។ ហេតុដូចនេះហើយ ទើបស្ថាប័នហិរញ្ញវត្ថុបានបង្កើតឱ្យមានការចូលឆែកយកព័ត៌មានបំណុលរបស់ អតិថិជន នៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានឥណទានកម្ពុជា ដើម្បីចៀសវាងហានិភ័យដែលអាចកើតមានឡើង ការក្លែងបន្លំ និងព័ត៌មានមិនពិតណាមួយ ដើម្បីជាជំនួយក្នុងការសម្រេចចិត្តផ្តល់ឥណទានដល់អតិថិជន។

ធនាគារស្ថាបនា ភីអិលស៊ី បានលើកកម្ពស់ស្ថេរភាពហិរញ្ញវត្ថុឱ្យកាន់ តែប្រសើរឡើង ដោយផ្តល់នូវ ទិន្នន័យទាន់ពេលវេលា និងជាក់លាក់ទៅកាន់អតិថិជន និងស្ថាប័នហិរញ្ញវត្ថុដែលជាសមាជិកក្នុងការជួយ ដល់ការគ្រប់គ្រងទិដ្ឋភាពហិរញ្ញវត្ថុ នៃអាជីវកម្មរបស់ពួកគេដោយអនុញ្ញាតឱ្យអាជីវកម្មទាំងមូលហើយក៏អាច គ្រប់គ្រងហានិភ័យឥណទាន ការពារការក្លែងបន្លំអត្តសញ្ញាណ និងធ្វើការសម្រេចចិត្តបានលឿន។ ធនាគារ ស្ថាបនា ភីអិលស៊ី ក៏បានផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋគ្រប់រូប ក្នុងការត្រួតពិនិត្យមើលរបាយការណ៍ ឥណទានផ្ទាល់ខ្លួន ដើម្បីធានាថាពួកគេអាចស្វែងរក និងទទួលបានប្រាក់កម្ចី និងការពារខ្លួនពីការលួចបន្លំអត្ត សញ្ញាណផងដែរ។

ដោយមើលឃើញពីសក្តានុពល និងដើម្បីធ្វើការសិក្សាស្រាវជ្រាវឱ្យកាន់តែច្បាស់លើសេវាកម្មនេះ ទើបក្រុមស្រាវជ្រាវយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទ ដែលទាក់ទងទៅនឹង **«ការគ្រប់គ្រង ហានិភ័យ ក្នុងការផ្តល់ឥណទានរបស់ធនាគារស្ថាបនា ភីអិលស៊ី»** មកធ្វើការសិក្សាស្រាវជ្រាវ ដើម្បីចងក្រង ជារបាយការណ៍បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនាពេលនេះ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីទទួលបាននូវព័ត៌មានការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារស្ថាបនា យើង គួរគប្បីសិក្សាទៅលើសំណួរដូចខាងក្រោម៖

១.តើនីតិវិធីនៃការផ្តល់ឥណទានរបស់ធនាគារស្ថាបនាប្រព្រឹត្តិទៅយ៉ាងដូចម្តេច?

២.តើហានិភ័យនៃការផ្តល់ឥណទានរបស់ធនាគារស្ថាបនាបណ្តាលមកពីកត្តាអ្វីខ្លះ?

៣.ដើម្បីគ្រប់គ្រងហានិភ័យឥណទានឱ្យមានប្រសិទ្ធភាព តើធនាគារស្ថាបនាមានមធ្យាបាយដូចម្តេច?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ យើងនឹងធ្វើការសិក្សាទៅលើ ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទាន របស់ធនាគារស្ថាបនា ភីអិលស៊ី ហើយការស្រាវជ្រាវនេះគឺមានគោលបំណងក្នុងការធ្វើឱ្យមានភាពរីកចម្រើន ដល់កត្តាចាំបាច់មួយចំនួន ដែលមានការទាក់ទងទៅនឹងប្រធានបទ ដោយបានផ្តោតការយកចិត្តទុកដាក់លើ បញ្ហាទាំងឡាយដែលបានចោទសួរនៅក្នុងចំណោទបញ្ហានៃការស្រាវជ្រាវ។យើងត្រូវធ្វើការសិក្សាផ្តោតទៅ លើ៖

- សញ្ញាណទូទៅនៃការផ្ដល់ឥណទានរបស់ធនាគារស្ថាបនា
- យល់ដឹងពីរបៀបនៃការត្រួតពិនិត្យឥណទានផ្ទាល់ខ្លួន
- ជៀសផុតពីការជាប់បំណុលច្រើនស្ថាប័ន
- ដំណោះស្រាយសម្រាប់អតិថិជន
- ដំណោះស្រាយសម្រាប់អាជីវកម្ម
- ផ្ដល់របាយការណ៍ឥណទានសម្រាប់ការវិភាគ និងសម្រេចចិត្តក្នុងការផ្ដល់ឥណទាន

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

ដោយសារពេលវេលាមានកំណត់ ហើយទិន្នន័យរបស់ការគ្រប់គ្រងហានិភ័យឥណទាន របស់ធនាគារស្ថាបនាមានច្រើន ហេតុដូចនេះ ក្រុមយើងខ្ញុំសូមលើកយកតែទិន្នន័យដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យឥណទានរបស់ធនាគារស្ថាបនា ដែលមានអាសយដ្ឋាន ស្ថិតនៅមហាវិថីព្រះនរោត្តម កែងផ្លូវលេខ១៧២ និងផ្លូវលេខ១៧៤ ភូមិភូមិ១៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវនេះ  គឺយើងធ្វើការសិក្សាស្រាវជ្រាវទៅលើតែការគ្រប់គ្រងហានិភ័យក្នុងការផ្ដល់ឥណទានរបស់ធនាគារ ស្ថាបនា នៅក្នុងឆ្នាំ២០២២ និង២០២៣ ដែលមានទីតាំងនៅផ្លូវព្រះនរោត្តម។ ចំពោះសេវាកម្មនេះ យើងនឹងធ្វើការសិក្សាទៅលើ របាយការណ៍ ឥណទានផ្ទាល់ខ្លួន របៀបស្នើសុំរបាយការណ៍ឥណទាន និងអត្ថប្រយោជន៍ របាយការណ៍ឥណទានអតិថិជន  សេវាវិភាគឥណទាន សេវាតាមដានឥណទាន សេវាត្រួតពិនិត្យឥណទាន ដំណោះស្រាយទិន្នន័យតាម តម្រូវការ នាពេលបច្ចុប្បន្ន ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

### ១.៥.២ ការប្រមូលទិន្នន័យបន្ទាប់

ជាប្រភពព័ត៌មានដែលទទួលបានតាមរយៈ ៖

- ឯកសារដែលមានស្រាប់នៅធនាគារស្ថាបនា
- ឯកសារដែលមាននៅបណ្ណាល័យ
- ឯកសារដែលផ្ដល់ដោយលោក លោកស្រីសាស្ត្រាចារ្យដែលខ្ញុំធ្លាប់បានសិក្សាកន្លងមក
- អនុសាសន៍របស់លោកសាស្ត្រាចារ្យណែនាំ
- តាមអ៊ីនធឺណែត និងតាមវេបសាយ

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

តាមការសិក្សាស្រាវជ្រាវនេះបានឆ្លុះបញ្ចាំងអំពីសារៈសំខាន់ និងអត្ថប្រយោជន៍ជាច្រើន៖

- ទទួលបានបទពិសោធន៍ដែលបង្កលក្ខណៈងាយស្រួលក្នុងការស្វែងរកការងារធ្វើ
- ទទួលបានបទពិសោធន៍ដែលបង្កលក្ខណៈងាយស្រួលក្នុងការស្នើរសុំឥណទាន
- ធ្វើឱ្យអ្នកស្រាវជ្រាវយល់ដឹងអំពីការងាររបស់ធនាគារក្នុងការគ្រប់គ្រងហានិភ័យឥណទាន
- ធ្វើឱ្យយើងដឹងពីការរៀបចំរចនាសម្ព័ន្ធក៏ដូចជាភារកិច្ចរបស់មន្ត្រីដែលធ្វើការនៅធនាគារស្ថានា

- អាចរក្សាទុកជាឯកសារដល់និស្សិតជំនាន់ក្រោយបានយល់ដឹងពីការគ្រប់គ្រងហានិភ័យឥណទាន។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវត្រូវបានបែងចែកជា ៥ ជំពូកដូចខាងក្រោម៖

**ជំពូកទី១ ៖ សេចក្តីផ្តើម** គឺជាការលើកឡើងនូវលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ( ទំហំ និងដែនកំណត់នៃ ការស្រាវជ្រាវ និងវិសាលភាពនៃការស្រាវជ្រាវ) វិធីសាស្ត្រនៃការស្រាវជ្រាវ (ទិន្នន័យដំបូង និងទិន្នន័យបន្ទាប់) រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២៖ រំលឹកទ្រឹស្តី** គឺនិយាយអំពីនិយមន័យ ទ្រឹស្តីពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យឥណទានរបស់ធនាគារស្ថាបនា សំដីរបស់អ្នកប្រាជ្ញលើកឡើងពីបទពិសោធន៍។

**ជំពូកទី៣៖ លទ្ធផលនៃការស្រាវជ្រាវ** គឺលើកយកនូវស្ថានភាពទូទៅ ប្រវត្តិរបស់ធនាគារស្ថាបនា រចនាសម្ព័ន្ធគ្រប់គ្រង គោលនយោបាយ បេសកកម្ម និងទស្សនវិស័យ ការងារគ្រប់គ្រង និងការងារបច្ចេកទេស។

**ជំពូកទី៤៖ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ** គឺការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ របស់ធនាគារស្ថាបនា បន្ទាប់ពីបានស្រាវជ្រាវរួចមកហើយ។

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងការផ្តល់សំណូមពរ** គឺជាការសរុបនូវទិន្នន័យទាំងមូល និងសំណូមពរ យ៉ាងណាដើម្បីឱ្យហានិភ័យឥណទានត្រូវបានធ្លាក់ចុះ។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២
# ការគ្រប់គ្រងហានិភ័យឥណទានរបស់ធនាគារ

## ២.១ លក្ខណៈទូទៅនៃការគ្រប់គ្រងហានិភ័យឥណទានរបស់ធនាគារ

### ២.១.១ និយមន័យធនាគារ

ធនាគារត្រូវបានគេកំណត់និយមន័យដូចខាងក្រោមៈ

- **ធនាគារ** គឺជាស្ថាប័នហិរញ្ញវត្ថុមួយ ដែលទទួលប្រាក់បញ្ញើ ដើម្បីដកតាមតម្រូវការ( ដូចជាសរសេរមូលប្បទានបត្រ ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច) ហើយនឹងផ្តល់ឥណទានទៅឱ្យសាធារណៈជន និងអាជីវកម្ម(ផ្តល់ឥណទានដល់អាជីវកម្មឯកជន ដើម្បីពង្រីកសន្និធិរបស់ទំនិញនៅក្នុងហាងរបស់ពួកគេ ឬដើម្បីទិញសម្ភារៈបរិក្ខាថ្មីៗ)[1]។
- **ធនាគារ** គឺជាស្ថាប័ន ឬគ្រឹះស្ថានទទួលប្រាក់បញ្ញើ ឬបណ្តាក់ទុនជាបណ្តាញប្រមូលប្រាក់សន្សំដោយឥតប្រើប្រាស់ ឬនៅទំនេរក្នុងសេដ្ឋកិច្ចយកទៅចែកចាយទៅតាមគ្រប់វិស័យសេដ្ឋកិច្ចតាមការផ្តល់ឥណទានដើម្បីជួយលើកស្ទួយសកម្មភាព និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម[2]។
- **ធនាគារ** គឺជាស្ថាប័នហិរញ្ញវត្ថុដែលធ្វើប្រតិបត្តិការ ផ្តល់នូវសេវាកម្មហិរញ្ញវត្ថុច្រើនប្រភេទដូចជាទទួលប្រាក់បញ្ញើ គ្មានមុខសញ្ញាប្រើប្រាស់ និងប្រាក់សន្សំពីសាធារណជន ផ្តល់ឥណទានឱ្យឯកតជន នឹងក្រុមហ៊ុនអាជីវកម្មជំនួញដោយយកការប្រាក់ព្រមទាំងផ្តល់សេវាទៅលើ ការងារទូទាត់ និងធ្វើវិនិយោគ ក្រោមរូបភាពជាសញ្ញាប័ណ្ណ និងមូលបត្រមានតម្លៃដើម្បីស្វែងរកប្រាក់ចំណេញសម្រាប់ម្ចាស់ក្រុមហ៊ុន[3]។
- **ធនាគារ** គឺជាគ្រឹះស្ថានសេវាហិរញ្ញវត្ថុដែលបានផលិត និងលក់មូលធនជាសាធារណៈប្រកបទៅដោយវិជ្ជាជីវៈ និងបានដើរតួយ៉ាងសំខាន់នៅក្នុងផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្ម។

### ២.១.២ ប្រវត្តិរបស់ធនាគារ

ដើមកំណើតនៃធនាគារ គឺគ្មានអ្នកណាម្នាក់ដឹងពិតប្រាកដទេនៃការចាប់កំណើតនោះ ប៉ុន្តែតាមការស្រាវជ្រាវបានឱ្យដឹងថា ធនាគារមានដើមកំណើតមកពីហាងមាស ឬជាងទង នៅសម័យបុរាណកាលជាង ២០០០ឆ្នាំមុន។ ហាងមាសទទួលប្រាក់បញ្ញើជាមាស និងវត្ថុមានតម្លៃផ្សេងៗទៀត ក្នុងករណីខ្លះក៏ផ្តល់ជាការប្រាក់លើការផ្ញើនេះដែរ។ នៅពេលដែលមានអតិថិជនយកមាសមកផ្ញើ អតិថិជននឹងទទួលបានវិក័យបត្រដែលចេញដោយហាងមាស ឬជាងទង ដោយបញ្ជាក់ពីចំនួនមាស ប្រភេទមាសដែលយកមកផ្ញើ។

ក្រោយពីអតិថិជនទទួលបានវិក័យបត្រពីហាងមាស ឬជាងទង អតិថិជនយល់ឃើញថាការទូទាត់ចំណាយដោយប្រើប្រាស់វិក័យបត្រមានភាពងាយស្រួលនិងមានសុវត្ថិភាពជាងការចាយមាស ឬប្រាក់ ដោយផ្ទាល់ ហើយចាប់ពីពេលនោះមកវិក័យបត្រដែលចេញដោយហាងមាស ឬជាងទង ក៏ដំណើរការដូចជា មាស ឬប្រាក់ ដែលបច្ចុប្បន្នវិក័យបត្រនោះក៏ក្លាយជាមូលប្បទានបត្រ (Check)។

[1] https://khemsarith.wordpress.com 24/02/2024
[2] https://m.facebook.com/permalink.php 24/02/2024
[3] https://images.app.goo.gl/U6xaCXTUXYsWwJYQA 24/02/2024

ដោយសារអតិថិជន យកមាសមកផ្ញើអាចរក្សាទុកនូវតម្លៃមួយថេរនៅក្នុងឃ្លាំង និងមានអតិថិជនមួយ ចំនួនបានដកមាសពីហាងមាស មួយចំនួនទៀតយកមកផ្ញើសារជាថ្មី ទើបម្ចាស់ហាងមាសបានផ្តល់កម្ចីទៅឱ្យអតិថិជនមួយចំនួនផ្សេងទៀតតាមរយៈការបោះវិក័យបត្របន្ថែមលើវិក័យបត្រចាស់ ចាប់តាំងពីពេលនោះមក ហាងមាសក៏ក្លាយទៅជាធនាគាររហូតមកដល់សព្វថ្ងៃ (នៅប្រទេសអ៊ីតាលី)។

ការអភិវឌ្ឍន៍នៃធនាគារបានរីករាលដាល ពីភាគខាងជើងប្រទេសអ៊ីតាលីទូទាំងចក្រភពរ៉ូមបរិសុទ្ធ ហើយនៅសតវត្សទី15 និងទី16 ទៅកាន់អឺរ៉ុបខាងជើងនេះត្រូវបានបន្តដោយការច្នៃប្រឌិតសំខាន់ៗមួយចំនួនដែលបានកើតឡើងនៅក្នុង Amsterdam ក្នុងអំឡុង សាធារណរដ្ឋហូឡង់ ក្នុងសតវត្សទី17 និងនៅទីក្រុងឡុងដ៍ចាប់តាំងពីសតវត្សទី18។ ក្នុងកំឡុងសតវត្សទី20 ការអភិវឌ្ឍន៍ផ្នែកទូរគមនាគមន៍ និងកុំព្យូទ័របាន បណ្តាលឱ្យមានការផ្លាស់ប្តូរយ៉ាងសំខាន់ចំពោះប្រតិបត្តិការរបស់ធនាគារ ហើយអនុញ្ញាតឱ្យធនាគារកើនឡើងយ៉ាងខ្លាំងនូវទំហំ និងការរីករាលដាលភូមិសាស្ត្រ។ វិបត្តិហិរញ្ញវត្ថុឆ្នាំ2007-2008 បានបណ្តាលឱ្យធនាគារជាច្រើនបរាជ័យ រួមទាំងធនាគារធំៗមួយចំនួនរបស់ពិភពលោក[4]។

**២.១.៣ ទ្រឹស្តីពាក់ព័ន្ធនៃធនាគារ**

ទ្រឹស្តីឥណទានបានទទួលស្គាល់ថាធនាគារមិនត្រឹមតែជាអន្តរការីនៃការសន្សំទេតែតាមពិត បង្កើតលុយដោយខ្លួនឯង។ គំនិតនេះត្រូវបានគេភ្ជាប់ជាមួយគណនីលម្អិត នៃដំណើរការបច្ចេកទេសនៃវិស័យធនាគារ។ ធនាគារមានតួនាទីសំខាន់ៗដូចខាងក្រោម៖

- **តួនាទីអន្តរការីៈ** បង្វែរការសន្សំជាសាច់ប្រាក់ ពីសាធារណជនទៅជាឥណទាន សម្រាប់សហគ្រាសពាណិជ្ជកម្មនិងសហគ្រាសផ្សេងទៀត ដើម្បីវិនិយោគនៅក្នុងការសាងសង់សម្ភារ បរិក្ខារ ឧបករណ៍ប្រើប្រាស់ និងសន្និធិ។ល។
- **តួនាទីទូទាត់ៈ** គឺជាការអនុវត្តនូវការទូទាត់ផ្សេងៗសម្រាប់ទំនិញ និងសេវាកម្មក្នុងនាមជាអតិថិជនរបស់ ពួកគេដូចជាការចេញ និងការទូទាត់មូលប្បទានបត្រ ផ្ទេរសាច់ប្រាក់ ការទូទាត់តាមប្រពន្ធ័អេឡិចត្រូនិច និង ការដកប្រាក់តាមប្រព័ន្ធម៉ាស៊ីនទំនើបអេធីអឹម(ATM)។
- **តួនាទីជាអ្នកធានាៈ** ឈរពីខាងក្រោយអតិថិជនរបស់គេដើម្បីធ្វើការទូទាត់ ឬសងនូវបំណុលរបស់អតិថិជន នៅពេលដែលអតិថិជនទាំងនោះ មិនអាចសងឱ្យទៅម្ចាស់បំណុលរបស់គេក្នុងកាលៈទេសៈចៃដន្យ ដោយធនាគារគ្រាន់តែចេញនូវលិខិតឥណទាន ដើម្បីបង្ហាញនូវទឹកប្រាក់នៅក្នុងគណនីអតិថិជនរបស់គេ។
- **តួនាទីគ្រប់គ្រងហានិភ័យៈ** ជួយទៅដល់អតិថិជនក្នុងការរៀបចំនៅ ការគ្រប់គ្រងប្រតិបត្តិការហិរញ្ញវត្ថុ សម្រាប់ការកើតមានហានិភ័យនៃការបាត់បង់ទ្រព្យសម្បត្តិ និងជីវិតមនុស្ស។
- **តួនាទីជាទីប្រឹក្សាលើការសន្សំៈ** ជួយដល់អតិថិជនលើ ការផ្តល់ការប្រឹក្សាយោបល់សម្រាប់ គោលដៅ រយៈពេលវែងក្នុងការធ្វើឱ្យមានជីវិតល្អប្រសើរ ដូចជាគម្រោងសាងសង់ ឬគម្រោងអាជីវកម្មផ្សេងៗ ដើម្បីជៀសវាងទុកប្រាក់សន្សំមិនចរាចរណ៍នៅលើទីផ្សារ។
- **តួនាទីជាអ្នកថែរក្សាវត្ថុមានតម្លៃៈ** ទុកដាក់វត្ថុមានតម្លៃរបស់អតិថិជន និងវាយតម្លៃប្រកបដោយសុក្រិត ភាពនូវតម្លៃរបស់ទ្រព្យសកម្ម ឬទ្រព្យសម្បត្តិដែលធ្វើប្រតិបត្តិការនៅលើទីផ្សារ។

[4] *https://en.m.wikipedia.org/wiki/History_of_banking 24/02/2024*

- **តួនាទីជាភ្នាក់ងារៈ** ក្នុងនាមជាអ្នកតំណាងឱ្យអតិថិជនដើម្បីចាត់ចែង និងការពារនូវទ្រព្យសកម្មរបស់ពួកគេ ឬចេញ និងលស់ ឬទទួលទូទាត់លក់ចេញ និងទិញចូលនូវប័ណ្ណភាគហ៊ុននានា។ ជាធម្មតា សកម្មភាពទាំងនេះត្រូវបានផ្តល់ឱ្យដោយនាយកដ្ឋានសច្ចភាពរបស់ធនាគារ។
- **តួនាទីអ្នកអនុវត្តគោលនយោបាយៈ** ធ្វើប្រតិបត្តិការស្របតាមគោលនយោបាយរបស់រដ្ឋាភិបាលក្នុងគោលបំណងឱ្យមានកំណើនសេដ្ឋកិច្ច និងឈានទៅដល់គោលដៅដែលសង្គមចង់បាន។

## ២.២ នីតិវិធីនៃការផ្តល់ឥណទានរបស់ធនាគារ

### ២.២.១ និយមន័យនីតិ

- **នីតិ** ជាបណ្តុំវិធានគតិយុត្តទាំងឡាយដែលមានគោលដៅធ្វើអោយសង្គមមនុស្សមានសណ្តាប់ធ្នាប់ និងអមមកជាមួយដោយទណ្ឌកម្ម[5]។
- **នីតិ** គឺជាសំណុំឯកសារនៃវិធានគតិយុតទាំងឡាយណាដែលត្រូវបានបង្កើតឡើងដើម្បីធ្វើការគ្រប់គ្រងឱ្យមានសណ្តាប់ធ្នាប់របស់សង្គម និងមានរបៀបរៀបរយល្អប្រសើរក្នុងសង្គមរស់នៅ[6]។
- **នីតិ** មានន័យថា ឧបាយជាគ្រឿងណែនាំ បែបផែន ជាទំនឹមទំនៀម ប្រពៃណី។ ឧទាហរណ៍៖ នីតិកម្ម(ការធ្វើច្បាប់ សិទ្ធិតែងច្បាប់ អង្គច្បាប់សម្រាប់រដ្ឋនីមួយៗ) នីតិកាល(រយៈពេលដែលសភាអ្នកតែងតាំងច្បាប់) នីតិបុគ្គល(អ្នករៀបរៀងច្បាប់) នីតីប្បញ្ញត្តិ(ការបង្គាប់ឱ្យធ្វើតាមច្បាប់ដែលតែងមក) នីតិក្រម(ទម្រង់របស់ច្បាប់ គឺសម្រាប់ចៅក្រមត្រូវអង្កេតពិនិត្យសាកសួរ ពីបទល្មើសផ្សេងៗ) ជាដើម[7]។

### ២.២.២ ប្រវត្តិនៃនីតិ

នៅសម័យសង្គមបុព្វកាលមនុស្សរស់នៅដោយគ្មានច្បាប់អ្វីទាំងអស់ទេ ប៉ុន្តែមនុស្សអាចរស់នៅជាមួយគ្នាបាន ហើយថែមទាំងមានការគោរពគ្នាទៅវិញទៅមកទៀតផង។ ការរស់នៅរបៀបនេះ គឺជាការរស់នៅតាមរយៈការគោរពនូវទំនៀមទម្លាប់ប្រពៃណីសាសនាជាដើម។ ប៉ុន្តែក្នុងពេលខ្លះក៏មានការរំលោភការធ្វើបាបការជិះជាន់ ការកេងប្រវ័ញ្ច និងការជំទាស់ប្រឆាំងគ្នាជានិរន្តរ៍ផងដែរ។ ទង្វើបែបនេះ ធ្វើឱ្យមនុស្សយល់ថាគួរតែរៀបចំឱ្យមាននូវឆន្ទៈរួមមួយ។ ឆន្ទៈរួមនេះ ធ្វើឱ្យវិវត្តន៍ទៅជាការរៀបចំក្បួនខ្នាតមួយចំនួន អំពីការរស់នៅរបស់មនុស្សតាមទម្លាប់ខាងលើ ដើម្បីជាការរក្សាទុក ក៏ដូចជាការបន្តការគោរពនូវទំនៀមទម្លាប់ និងប្រពៃណីខាងលើនាពេលក្រោយៗទៀត។

ភស្តុតាងជាក់ស្តែងជាច្រើនបានបង្ហាញឱ្យឃើញថា ច្បាប់បានករកើតឡើងតាំងពីយូរលង់ណាស់មក ហើយពោលគឺតាំងពីសម័យដើមមកម្ល៉េះ គឺតាំងពីសម័យកាលដែលមនុស្សចេះរួបរួមគ្នារស់នៅជាក្រុម ជាពួក ជាកុលសម្ព័ន្ធ ដោយត្រូវមានក្រុមមេពួកឬមេកន្ទ្រាញ (ស្តេចក្រាញ់)។ មេក្រុម មេពួក មេកន្ទ្រាញ តែងតែរិះរកគំនិតនិងប្រធានផ្សេងៗ ដើម្បីធ្វើការគ្រប់គ្រងកូនចៅរបស់ខ្លួន។ ការគ្រប់គ្រងនេះហើយដែលជាការចាប់ផ្តើម ក៏កើតនូវច្បាប់មួយដែលមេក្រុម មេពួក ឬមេកន្ទ្រាញខ្លះ គ្រប់គ្រងតាមបែបផ្តាច់ការ និងខ្លះទៀតមិនផ្តាច់ការ រហូតដល់មានជាការគ្រប់គ្រងដោយព្រះរាជា ដែលព្រះរាជា ធ្វើការគ្រប់គ្រងនគរការពារអំណាច

---

[5] https://www.facebook.com 24/02/2024

[6] https://m.tnaot.com/km/m/detail/article/2127308 24/02/2024

[7] *«ច្បាប់, នីតិ និងវិន័យ» តើមានលក្ខណៈខុសគ្នាដូចម្តេច? (thmeythmey.com)* (24/02/24)

ការពារតំណែង និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជារាស្ត្របាន។ ទាំងនេះ គឺជាការបញ្ជាក់អំពីភាពរីកចម្រើននៃកំណើតរបស់ច្បាប់។

យ៉ាងណាច្បាប់ប្រទេសកម្ពុជា យើងអាចមើលឃើញថា តើមានការលំបាកយ៉ាងណាខ្លះក្នុងបេសកកម្មកសាងប្រជានអង្គរវត្ត។ ជាការពិតណាស់ក្នុងដំណើរការកសាងនេះ គឺពិតជាមានការលំបាកយ៉ាងខ្លាំងទាំងបច្ចេកទេសធនធានមនុស្ស និងការគ្រប់គ្រងពិសេសគឺការសាងសង់។ ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ គឺត្រូវទាមទារឱ្យមាននូវច្បាប់នៃការគ្រប់គ្រងសង្គមមួយ ដ៏មានប្រសិទ្ធិភាពនិងភាពស័ក្តិសិទ្ធិ។

ដូចនេះ យើងអាចនិយាយជារួមបានថា គឺពិតជាមានតាំងពីយូរយាណាស់មកហើយ គ្រាន់តែយើងមិនមានឯកសារបញ្ជាក់ច្បាស់លាស់តែប៉ុណ្ណោះ ប៉ុន្តែ យើងអាចមើលទៅលើភស្តុតាងមួយចំនួនដែលទុកដូចជាប្រាសាទអង្គរវត្តមហាកំពែងចិន...។ ដែលសុទ្ធតែជាភស្តុតាងបញ្ជាក់អំពីការកកើតច្បាប់។

**២.២.៣ ទ្រឹស្តីពាក់ព័ន្ធនឹងនីតិ**

**+ ចំពោះមនុស្សនិងមនុស្ស**

- ទប់ស្កាត់ជម្លោះ
- ដោះស្រាយជម្លោះ
- ផ្តល់នូវយុត្តិធម៌
- ការពារមនុស្ស សេរីភាពនិងទ្រព្យសម្បត្តិផ្សេងៗ។

**+ចំពោះប្រជារាស្ត្រនិងរដ្ឋ**

- កំណត់អំណាចរបស់រដ្ឋ
- កំណត់សេរីភាពរបស់បុគ្គលផ្តល់ដំណោះស្រាយនៃជម្លោះរវាងរាស្ត្រនិងរដ្ឋការពារសង្គមមនុស្ស និងពូជមនុស្ស។

លោកCicéron(106-43មុនគ.ស )ជនជាតិរ៉ូម៉ាំងបានបែងចែកនីតិជា៣ប្រភេទគឺៈ

- នីតិធម្មជាតិ
- នីតិវិជ្ជមាន
- នីតិប្រជាជាតិឬនីតិអន្តរជាតិ។

**+ការបែងចែកជានីតិជាតិនិងនីតិអន្តរជាតិ**

នីតិជាតិគឺជាច្បាប់សម្រាប់គ្រប់គ្រងនីមួយៗហើយមានអនុភាពអនុវត្តតែនៅលើផែនដីឬរដ្ឋនៅតែប៉ុណ្ណោះ។

នីតិអន្តរជាតិគឺជាច្បាប់សម្រាប់គ្រប់គ្រងទំនាក់ទំនងរដ្ឋ និងរដ្ឋ ឬរវាងរដ្ឋនិងអង្គការអន្តរជាតិ។ ក្នុងក្របខណ្ឌអន្តរជាតិគេត្រូវបង្កើតច្បាប់ថ្មីមួយទៅរយៈការចរចារវាងរដ្ឋនិងរដ្ឋ ព្រោះរដ្ឋមានអធិបតេយ្យរៀងៗខ្លួនមិនចំណុះក្រោមច្បាប់ជាតិណាមួយឡើយ។

**+នីតិសាធារណៈ និងនីតិឯកជន**

នីតិសាធារណៈ៖ គឺជានីតិដែលគ្រប់គ្រងទំនាក់ទំនងរវាងអំណាចរដ្ឋនិងបុគ្គលឯកជន។

នីតិឯកជន ៖ គឺជានីតិដែលគ្រប់គ្រងទំនាក់ទំនងរវាងបុគ្គលឯកជននិងបុគ្គលឯកជន។

**+នីតិវត្ថុនិស័យនិងនីតិអន្តរវិស័យ**

នីតិវត្ថុនិស្ស័យ (Droit objective/Objective law)គឺជាវិធានទាំងឡាយណាដែលគ្រប់គ្រងជីវភាពរស់នៅក្នុងសង្គមដោយមានការដាក់ទណ្ឌកម្មពីអាជ្ញាធរសាធារណៈ។

នីតិអត្តវិស័យ(Droit Subjective/Subjective Law)គឺជាបុព្វសិទ្ធិដែលច្បាប់ទទួលស្គាល់ចំពោះបុគ្គលសម្រាប់ប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួនព្រមទាំងទទួលបានការពារពីច្បាប់។

## ២.៣ កត្តាដែលធ្វើឱ្យមានហានិភ័យឥណទាន

### ២.៣.១ និយមន័យនៃពាក្យឥណទាន

ឥណទានត្រូវបានគេកំណត់និយមន័យជាច្រើនមានដូចនៅខាងក្រោម៖

**ឥណទាន(Credit)** គឺជាការឱ្យខ្ចីប្រាក់ដែលមានចងជាកិច្ចសន្យាត្រឹមត្រូវ ហើយអ្នកខ្ចីប្រាក់មានកាតព្វកិច្ចប្រើប្រាស់ប្រាក់កម្ចីអោយបានស្របច្បាប់ និងសងត្រលប់មកវិញនូវប្រាក់ដើម ការប្រាក់ និងបន្ទុកហិរញ្ញវត្ថុផ្សេងៗទៀតដែលមានចែងកិច្ចសន្យាឱ្យបានទៀងទាត់[8]។

**ឥណទាន(Credit)** គឺជាការផ្តល់នូវចលនទ្រព្យឬអចលទ្រព្យ ឱ្យទៅអ្នកមានតម្រូវការលើ ទ្រព្យទាំងនោះ ដោយតម្រូវឱ្យសងវិញតាមលក្ខខ័ណ្ឌមួយច្បាស់លាស់ [9]។

**ឥណទាន(Credit)** គឺជាការសន្យាសងនៅពេលអនាគត ក្នុងគោលបំណងដើម្បីទិញជំពាក់ ឬសុំខ្ចីនៅពេលបច្ចុប្បន្ន[10]។

### ២.៣.២ ប្រវត្តិនៃឥណទាន

ឥណទានបានចាប់ផ្តើមនៅឆ្នាំ1987 ដោយអង្គការ UNICEF ដែលការចាប់ផ្តើមនេះបានផ្តល់ជារបៀបឥណទានសត្វគោ។ ព្រោះថា ក្រោយពីសង្គ្រាមរួចមកបានបន្សល់ទុកនូវស្ត្រីមេម៉ាយ ចាស់ជរា ក្មេងកំព្រាជាច្រើន ដែលជាមេគ្រួសារ ហើយពួកគេមានការខ្វះខាតកម្លាំងពលកម្មបុរសនិងកម្លាំងអូសទាញសម្រាប់ការងារកសិកម្ម។ នៅឆ្នាំ1991 អង្គការ GREAT (Group Exchange des Technique) ដែល ទទួលបានឥណទានពីភ្នាក់ងារអភិវឌ្ឍនៃប្រទេសបារាំង (Agene Francoise de Development) បានបង្កើតអង្គការមួយដែលមានឈ្មោះថា អង្គការមូលដ្ឋានឥណទាន។ អង្គការនេះបានសាកល្បងឥណទាន ដំបូងនៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ដែលផ្តល់ជាជី និងពូជស្រូវ តែប៉ុណ្ណោះ។ក្រោយៗមកមានធនាគារនិងអង្គការជាច្រើន បានចូលរួម ចំណែកប្រតិបត្តិការមីក្រូហិរញ្ញវត្ថុដូចជា ធនាគារអេស៊ីលីដា សិលាលីមីតធីត ស្ថាបនាសហគ្រិន និងធនាគារដទៃផ្សេងៗជាច្រើនទៀត រហូតមកដល់សព្វថ្ងៃ។

### ២.៣.៣ មុខងារផ្តល់ឥណទាន

មុខងារផ្តល់ឥណទាន (Credit: Function) គឺជាមុខងារដ៏សំខាន់របស់ធនាគារដែលអាចឱ្យ ធនាគាររកប្រាក់ចំណេញបានយ៉ាងខ្ពស់តាមរយៈចំណូលការប្រាក់ពីសកម្មភាពនៃការផ្តល់ឥណទាន និងមានកម្ចីគ្រប់ប្រភេទរបស់ខ្លួនទៅឱ្យអតិថិជន។ ជាទូទៅឥណទានមានច្រើនប្រភេទ ដូចជា ៖

[8] https://www.facebook.com/profile.php?id=100038469349584 24/02/2024
[9] http://ocsrp.blogspot.com/2016/05/blog-post_78.html?m=1 24/02/2024
[10] https://www.facebook.com/Khemsarithedu 24/02/2024

- **ឥណទានអាជីវកម្ម ឬពាណិជ្ជកម្ម** គឺជាឥណទានមួយប្រភេទ ដែលធនាគារផ្តល់ជូនអតិថិជន សម្រាប់យកទៅប្រកបមុខរបរក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ។
- **ឥណទានសម្រាប់អ្នកប្រើប្រាស់** គឺជាឥណទានមួយប្រភេទដែលធនាគារផ្តល់ជូនអតិថិជន សម្រាប់យកទៅប្រើប្រាស់ផ្ទាល់ខ្លួន មានដូចជា ដោះស្រាយបញ្ហាក្នុងគ្រួសារ បន្តការសិក្សា ព្យាបាលជំងឺ ឬសម្រាប់រៀបអាពាហ៍ពិពាហ៍ជាដើម...។
- **ឥណទានអន្តរធនាគារ** គឺជាឥណទានមួយប្រភេទដែលធនាគារខ្ចីពីធនាគារ សម្រាប់យកទៅ វិនិយោគបន្ត។
- **កម្ចីកសិកម្ម** គឺជាកម្ចីមួយប្រភេទដែលធនាគារផ្តល់ជូនអតិថិជន សម្រាប់យកទៅធ្វើស្រែចម្ការ ឬដាំដំណាំជាដើម។

➤ **ការចាត់ថ្នាក់របស់ឥណទានបែកចេញជា២ ថ្នាក់ ៖**

ឥណទានឯកជនគឺជាឥណទានមួយប្រភេទដែលធនាគារផ្តល់ជូនទៅឱ្យបុគ្គល ឬស្ថាប័ន ទាំងឡាយណាដែលស្ថិតនៅក្នុងវិស័យឯកជន សម្រាប់យកទៅប្រើប្រាស់ ឬវិនិយោគផ្សេងៗ។ ឥណទានឯកជនបែកចេញជា២ ពី ៖

☞ ឥណទានអ្នកប្រើប្រាស់ ចែកចេញជា៣ គឺ ៖

- ឥណទានរាយ
- ឥណទានសាច់ប្រាក់
- ឥណទានអចលនទ្រព្យ

☞ ឥណទានអាជីវកម្ម ចែកចេញជា២ គឺ ៖

- ឥណទានសម្រាប់ទិញ លក់ទំនិញ
- ឥណទានមូលធនហិរញ្ញវត្ថុ

ឥណទានសាធារណៈ គឺជាឥណទានមួយប្រភេទដែលធនាគារផ្តល់ជូនរដ្ឋាភិបាល សម្រាប់យកទៅអភិវឌ្ឍន៍ប្រទេសជាតិ តាមរយៈការទិញប័ណ្ណបំណុលរបស់រដ្ឋាភិបាល។

➤ **ដំណើរការនៃការផ្តល់ឥណទានផ្តោតទៅលើកត្តា៦យ៉ាង ៖**

**ចរិកលក្ខណៈ (Character)** គឺជាចំនួនអរូបិយដែលយើងមិនអាចចាប់កាន់បាន វានឹងបង្ហាញឱ្យឃើញតាមរយៈសកម្មភាពផ្សេងៗ។ លក្ខណៈមានសារសំខាន់ណាស់សម្រាប់អ្នកផ្តល់ឥណទាន ដើម្បីតាមដានទៅលើការរស់នៅ ប្រវត្តិសងប្រាក់ ប្រវត្តិខ្ចីប្រាក់។

**មូលធនដើមទុន(Capital)** គឺបង្ហាញអំពីទ្រព្យសម្បត្តិរបស់អ្នកស្នើសុំឥណទាន ក្នុងការសង ត្រលប់មកវិញ នៅពេលដែលបាត់បង់ការងារ ឬចំណូល។

**សមត្ថភាព (Capacity)** គឺបង្ហាញពីលទ្ធភាពដែលអ្នកស្នើសុំឥណទាន អាចសងត្រលប់មកវិញឱ្យបានទាន់ពេលវេលា និងគ្រប់ចំនួនតាមការព្រមព្រៀងដែលបានស្នើសុំ។

**លក្ខខណ្ឌ (Condition)** គឺសំដៅទៅលើកិច្ចព្រមព្រៀងរវាងអ្នកផ្តល់ឥណទាន និងអ្នកស្នើសុំឥណទានក្នុងការសងត្រឡប់មកវិញ។

**ទ្រព្យបញ្ចាំ ឬទ្រព្យធានា (Collateral)** គឺសំដៅទៅលើទ្រព្យសម្បត្តិដែលអ្នកស្នើសុំឥណទានមានយកមកធ្វើការធានា ឬបញ្ចាំ។

**មុខងារទូទាត់ (Payment Function)** គឺជាមុខងាររបស់ធនាគារ ដើម្បីជួយសម្រួលក្នុងការ ដោះដូរទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗ តាមរយៈប្រព័ន្ធអេឡិចត្រូនិចមានដូចជា ATM Card,VISA Card, Credit Card, Check,... ។

## ២.៤ មធ្យោបាយនៃការគ្រប់គ្រងហានិភ័យឥណទាន

### ២.៤.១ និយមន័យនៃពាក្យគ្រប់គ្រង

- **ការគ្រប់គ្រង (Management)** គឺជាដំណើរការនៃការប្រើប្រាស់ធនធាន នៅក្នុងអង្គភាពឱ្យទទួលបានជោគជ័យដល់អង្គភាព ដោយមានការរៀបចំ ការធ្វើផែនការ ការដឹកនាំ និងការត្រួតពិនិត្យ[11] ។
- **ការគ្រប់គ្រង(Management)**គឺដំណើរការធ្វើផែនការ ចាត់តាំង ដឹកនាំ និងត្រួតពិនិត្យ ទៅលើការប្រើប្រាស់ធនធានមនុស្ស និងធនធានដទៃទៀតដើម្បីសម្រេចគោលដៅអង្គភាព ។
- **ការគ្រប់គ្រង**(Management) គឺជាដំណើរការនៃការធ្វើការជាមួយនឹងមនុស្ស និងធនធានដទៃទៀតដើម្បីសម្រេចបាននូវគោលដៅរបស់អង្គភាព[12]។
- **ការគ្រប់គ្រង(Management)** គឺជាបណ្តុំនៃសកម្មភាពដែលបង្កើតឡើង ដើម្បីធ្វើឱ្យសម្រេចនូវគោលបំណងរបស់អង្គភាព តាមរយៈការប្រើធនធាននានា (Resources) ឱ្យប្រកបដោយប្រសិទ្ធភាព (Effectively) និងសក្តិសិទ្ធិភាព(Efficiently)។ តាមរយៈនិយមន័យនេះ ដើម្បីសម្រេចគោលដៅរបស់អង្គភាព អ្នកគ្រប់គ្រងត្រូវតែចេះប្រើធនធានដែលខ្លួនមានប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព ឬបើនិយាយឱ្យស្រួលយល់ គឺត្រូវប្រើធនធានដើម្បីសម្រេចគោលដៅផងនិងប្រើឱ្យបានត្រឹមត្រូវផង[13]។

### ២.៤.២ ប្រវត្តិនៃការគ្រប់គ្រង

គំនិតនៃការគ្រប់គ្រងមានតាំងពីរាប់ពាន់ឆ្នាំមកហើយ។ យោងតាម Pindur ហើយ Kim1995 វិធីសាស្រ្តសំខាន់ៗ ក្នុងការគ្រប់គ្រងបានត្រឡប់មកវិញយ៉ាងហោចណាស់ 3000ឆ្នាំមុន ពេលកំណើតរបស់ព្រះគ្រីស្ទ ដែលជាពេលវេលាមួយដែលបានកំណត់ត្រា នៃការធ្វើជំនួញត្រូវបានកាត់ត្រាជាលើកដំបូងដោយពួកបូជាចារ្យនៅមជ្ឈិមបូព៌ា។ សូក្រាតនៅប្រហែលឆ្នាំ400 មុនគ្រីស្តសករាជ បាននិយាយថាការគ្រប់គ្រងគឺជាសម្ថភាពដោយដាច់ដោយឡែកពីជំនាញបច្ចេកទេស នឹងចំណេះដឹង(Huggins1991)។ ជនជាតិរ៉ូមដែលល្បីល្បាញដោយសារកងទ័ពទាហានរបស់ពួកគេដឹកនាំដោយ Centurion បានផ្តល់ការទទួលខុសត្រូវតាមរយៈឋានានុក្រមនៃសិទ្ធិអំណាច។ ព្រះវិហាររ៉ូម៉ាំងកាតូលិកត្រូវបានរៀបចំតាមបន្ទាត់នៃទឹកដីជាក់លាក់ខ្សែសង្វាក់នៃពាក្យបញ្ជានិងការពិព័រណ៍ធនាការងារ។ ក្នុងកំឡុងយុគសម័យកណ្តាលជាង រយៈពេល1000ឆ្នាំ ប្រហែលពីឆ្នាំ476 នៅគ.ស ដល់1450 គ.ស Guilds ដែលជាបណ្តុំនៃសិប្បករនិងពាណិជ្ជករបានផ្តល់ទំនិញដែលធ្វើដោយដៃរាប់ចាប់ពីនំប៉័ងរហូតដល់ពាសដែក និងជាវសម្រាប់ បូជនីយកិច្ច។ ឋានានុក្រមនៃការគ្រប់គ្រងនិងអំណាចស្រដៀងទៅនឹងព្រះវិហារកាតូលិកដែលមាននៅក្នុងនោះអាជ្ញាធរបានសម្រាកជាមួយចៅហ្វាយនាយហើយបោកបញ្ឆោតទៅកាន់អ្នកធ្វើដំណើរ និងកូនជាង។ ជាទូទៅសិប្បករណ៍ទាំងនេះ គឺជាអាជីវកម្មខ្នាត

[11] https://www.khsearch.com/qna/24819 24/02/24
[12] https://clubniset.wordpress.com/ 24/02/24
[13] https://www.facebook.com/ 24/02/24

តូច ដែលផលិតផលដែលមានកម្រិតគុណភាពខុសៗគ្នាអត្រាផលិតទាបនិងតម្រូវការតិចតួចសម្រាប់ការគ្រប់គ្រងលើសពីម្ចាស់ ឬសិប្បកររមេ។

បដិវត្តន៍ឧស្សាហកម្មដែលជាពេលវេលាមួយចុងទសវត្សរ៍ឆ្នាំ1700 ដល់ទសវត្សរ៍ឆ្នាំ1800 គឺជារយៈពេលនៃភាពចលាចលនិងការផ្លាស់ប្តូរដ៏ធំនៅក្នុងរបៀបរស់នៅនិងការងាររបស់មនុស្ស។ មុននេះប្រជាជនភាគច្រើនប្រកបរបរធ្វើស្រែចម្ការ ឬធ្វើការ និងរស់នៅក្នុងសហគមន៍ជនបទ។ ជាមួយនឹងការបង្កើតម៉ាស៊ីនចំហាយទឹក ការច្នៃប្រឌិតជាច្រើនបង្កើតឡើង រួមទាំងចលនាដល់ស្វ័យប្រវត្តិនៃធ្យូងថ្មពីអណ្តូងរ៉ែក្រោមដីរោងចក្រថាមពលដែលឥឡូវនេះទំនិញផលិតផលយ៉ាងច្រើនដែលផលិតដោយដៃ និងក្បាលរថភ្លើងផ្លូវដែកដែលអាចផ្លាស់ទីផលិតផលនៅសម្ភារៈឆ្លងកាត់ប្រទេសនានាបានទាន់ពេលវេលានិងវិធីមានប្រសិទ្ធភាព។ រោងចក្រត្រូវការកម្មករដែលទាមទារទិសដៅនិងអង្គការ។ ដោយសារគ្រឿងបរិក្ខាទាំងនេះកាន់តែមានសារៈសំខាន់និងលទ្ធភាពតម្រូវការសម្រាប់គ្រប់គ្រងនិងការសម្របសម្រួលបានក្លាយជាកត្តាសំខាន់។ គិតអំពី Henry Ford ដែលជាបុរសបានបង្កើតឡើងខ្សែដំឡើងចល័តដើម្បីផលិតរថយន្តរបស់គាត់។ នៅដើមសតវត្សឆ្នាំ1900 រថយន្តត្រូវបានដាក់បញ្ចូលគ្នាដោយសប្បិករដែលនឹងកែប្រែសមត្ថភាពឱ្យ សមនឹងផលិតផលរបស់ពួកគេ។ នៅឆ្នាំ1913 ពេលវេលាដែលត្រូវការក្នុងការកសាងសង់គំរូT បានធ្លាក់ចុះពីប៉ុន្មានថ្ងៃត្រឹមតែប៉ុន្មានម៉ោងប៉ុណ្ណោះ (Kleass,2020)។ តាមទស្សនៈរបស់អ្នកគ្រប់គ្រងសិប្បករដែលមានជំនាញគ្រប់គ្រងប្រតិបត្តិការដ៏ធំទាំងនេះ (Wilson,2015)។ ដើម្បីទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យាថ្មីៗ វិធីសាស្ត្រផ្សេងគ្នា ចំពោះរចនាសម្ព័ន្ធស្ថាប័ននិងការគ្រប់គ្រងត្រូវបានទាមទារ[14]។

### ២.៤.៣ ទ្រឹស្តីពាក់ព័ន្ធនៃការគ្រប់គ្រង

ការគ្រប់គ្រងជាសកម្មភាពទាំងឡាយដែលថ្នាក់ដឹកនាំបង្កើតឡើង ដើម្បីលើកកម្ពស់លទ្ធភាព ធានាឱ្យគោលដៅបានកំណត់អាចសម្រេចបាន។ សកម្មភាពទាំងនោះអាចជាសកម្មភាពការពារ( ទប់ស្កាត់ កុំឱ្យព្រឹត្តិការណ៍ អាក្រក់កើតឡើង) ស្វែងរក និងកែលម្អនូវព្រឹត្តិការណ៍អាក្រក់ដែលបានកើត) ឬតម្រង់ទិស (ជំរុញឱ្យ ព្រឹត្តិការណ៍ល្អកើតឡើង)។

### គោលបំណងនៃការគ្រប់គ្រង

គោលបំណងនៃការគ្រប់គ្រង សំដៅលើគោលដៅជាក់លាក់ និងគោលដៅដែលអង្គភាព ឬស្ថាប័នកំណត់ដើម្បីដឹកនាំសកម្មភាពគ្រប់គ្រងរបស់ខ្លួន និងជំរុញឱ្យទទួលបានជោគជ័យជារួម។ គោលបំណងទាំងនេះជាធម្មតាត្រូវបានបង្កើតឡើងដោយអ្នកគ្រប់គ្រងកម្រិតកំពូល ឬនាយកប្រតិបត្តិ ហើយត្រូវបានទម្លាក់ទៅកម្រិតទាបនៅក្នុងអង្គភាព ឬស្ថាប័ន។ គោលបំណងនៃការគ្រប់គ្រងផ្តល់នូវទិសដៅច្បាស់លាស់និងការផ្តោតអារម្មណ៍សម្រាប់អ្នកគ្រប់គ្រង និងបុគ្គលិក ដោយជួយតម្រង់ការខិតខំប្រឹងប្រែងរបស់ពួកគេឆ្ពោះទៅរកការសម្រេចបាននូវគោលដៅរបស់អង្គភាព ឬស្ថាប័ន។ គោលបំណងនៃការគ្រប់គ្រងជាក់លាក់អាចប្រែប្រួលអាស្រ័យលើឧស្សាហកម្ម ទំហំ និងអាទិភាពយុទ្ធសាស្ត្ររបស់អង្គភាព ឬស្ថាប័ន។ និយាយឱ្យងាយស្រួលយល់ គឺការគ្រប់គ្រងធ្វើឡើងដើម្បីឱ្យមានរបៀបរបបការងារនិងបង្កើនប្រសិទ្ធភាពការងារ[15]។

**ការគ្រប់គ្រងគឺសំដៅទៅលើមុខងារ៤ គឺ៖**

[14] https://fhsu.pressbooks.pub/management/chapter/the-history-of-management/ 24/02/2024
[15] https://www.khsearch.com/qna 24/02/2024

ក. ផែនការសកម្មភាពការងារច្បាស់លាស់ និងស្របតាមធនធានដែលអង្គភាពមាន។

ខ. ការចាត់តាំង ឬចាត់ចែងការងារជូនបុគ្គលិកឱ្យត្រូវតាមជំនាញឯកទេសរបស់ពួកគេ ។

គ. ការដឹកនាំបានល្អ ត្រឹមត្រូវ និងស្របទៅនឹងវប្បធម៌របស់អង្គភាព និងតាមតំបន់ ។

ឃ. ត្រួតពិនិត្យទៅលើរាល់លទ្ធផលការងារដែលបុគ្គលិកអនុវត្តកន្លងមក។

មុខងាទាំងអស់នេះប្រើសម្រាប់សម្រេចគោលបំណង និងគោលដៅរបស់អង្គភាព។

**ការគ្រប់គ្រងមាន៣ ប្រភេទ៖**

**ក.ការគ្រប់គ្រងផ្នែកគណនេយ្យ** គឺទាក់ទងនឹងការកត់ត្រា ការគណនា ការបូកសរុប និងការាយការណ៍អំពីប្រតិបត្តិការហិរញ្ញវត្ថុ។ ការគ្រប់គ្រងទាំងនេះ កាត់បន្ថយនូវកំហុសជាយថាហេតុ ឬការកេងបន្លំ និងធានានូវភាពត្រឹមត្រូវនៃព័ត៌មាន តាមការបែងចែកកាតព្វកិច្ច ឱ្យដាច់ពីគ្នាការផ្ទៀងផ្ទាត់ដោយឯករាជ្យ ប្រព័ន្ធប្រតិភូកម្មអំណាចសមស្រប។

**ខ.ការគ្រប់គ្រងផ្នែករដ្ឋបាល** គឺជាការគ្រប់គ្រងកម្រិតខ្ពស់របស់ថ្នាក់ដឹកនាំ។ ការគ្រប់គ្រងនេះ អនុញ្ញាតឱ្យថ្នាក់ដឹកនាំបានដឹងអំពីលទ្ធផលនៃការអនុវត្តភារកិច្ច ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួនតាមរយៈការគ្រប់គ្រងទាក់ទងនឹងរចនាសម្ព័ន្ធរបស់អង្គភាពនីតិវិធី និងរបាយការណ៍ ជូនថ្នាក់ដឹកនាំស្តីពីថវិការ និងការប្រៀបធៀបលទ្ធផលផ្សេងៗទៀតធៀបនឹងគោលដៅ ដើម្បីទទួលបាននូវមតិឆ្លើយតប ការវិភាគ និងវិធានការកែតម្រូវ។

**គ.ការគ្រប់គ្រង ផ្នែកប្រតិបត្តិការ** គឺជាការគ្រប់គ្រងដែលទាក់ទងនឹងសកម្មភាពផ្សេងពីកិច្ចការ ហិរញ្ញវត្ថុដែលបំពេញដោយមន្ត្រីមិនមែនថ្នាក់ដឹកនាំពោល គឺការគ្រប់គ្រងដែលបានបង្កើតឡើង ក្នុងការដំណើរការផលិត ឬប្រតិបត្តិការដើម្បីធានាថា អង្គភាពបានផលិតទំនិញ ឬផ្គត់ផ្គង់សេវាប្រកបដោយ ប្រសិទ្ធភាព និង ប្រសិទ្ធផល ។

# ជំពូកទី៣

# លទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៣

# ការគ្រប់គ្រងហានិភ័យក្នុងផ្តល់ឥណទានរបស់ធនាគារស្ថាបនា ភីអិលស៊ី

## ៣.១ ស្ថានភាពទូទៅនៃធនាគារស្ថាបនា ភីអិលស៊ី

### ៣.១.១ ប្រវត្តិរបស់ធនាគារស្ថាបនា ភីអិលស៊ី



ម្ចាស់ក្រុមហ៊ុនផ្ទាល់របស់ធនាគារស្ថាបនា ភីអិលស៊ី គឺជាសាជីវកម្មម៉ារ៉ូហាន់របស់ជប៉ុនដែលបានបង្កើតឡើងតាំងពីខែឧសភា ឆ្នាំ១៩៧៥ ដោយលោកបណ្ឌិត Han Chang-Woo ប្រធានក្រុមប្រឹក្សាភិបាល ហើយបច្ចុប្បន្នគឺជាក្រុមហ៊ុនពហុកំសាន្តឈានមុខគេក្នុងប្រទេសជប៉ុន។ នាពាក់កណ្តាលទសវត្សឆ្នាំ២០០០ លោកបណ្ឌិត Han Chang-Woo បានធ្វើកំណើរទេសនកិច្ច នៅតាមបណ្តាប្រទេសមួយចំនួនក្នុងតំបន់អាស៊ីអាគ្នេយ៍ដើម្បីសិក្សាស្វែងយល់ពីសក្តានុពល និងឱកាសអាជីវកម្មថ្មីៗក្នុងគោលបំណងបង្កើនសេដ្ឋកិច្ច និងជួយប្រជាពលរដ្ឋរបស់ប្រទេសទាំងនោះឱ្យមានជីវភាពប្រសើរឡើង។ លោកបណ្ឌិត Han Chang-Woo មានបទពិសោធន៍ ក្នុងកំឡុងពេលដែលប្រទេសជប៉ុន ចាប់ផ្តើមមានភាពរីកចម្រើនពីទសវត្សឆ្នាំ១៩៥០ រហូតដល់បច្ចុប្បន្ន។ គាត់បានជួបប្រាស្រ័យទាក់ទងជាមួយមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ និងពាណិជ្ជករដើម្បីទទួលបាននូវយោបល់ និងការពិភាក្សាផ្សេងៗ។ លោកបណ្ឌិត បានចាប់អារម្មណ៍ជាពិសេស ចំពោះប្រទេសកម្ពុជា ហើយគាត់មានអារម្មណ៍ថា ប្រទេសកម្ពុជាមានសក្តានុពលបន្ទាប់ពីបានឆ្លងកាត់បទពិសោធន៍ដ៏លំបាកបំផុតក្នុងសម័យសង្គ្រាមស៊ីវិល។ លោកបណ្ឌិត យល់ឃើញថា ការបង្កើតធនាគារពាណិជ្ជជាមួយនឹងការធ្វើបដិសណ្ឋារកិច្ចតាមបែបជប៉ុន ពិតជាអាចជួយ និងចូលរួមចំណែក ក្នុងការអភិវឌ្ឍន៍ភាពរីកចម្រើនរបស់ប្រទេសកម្ពុជា។

ដោយហេតុនេះ លោកបណ្ឌិត Han Chang-Woo បានបង្កើត ម៉ារ៉ូហាន់ ធនាគារជប៉ុន ភីអិលស៊ី ក្នុងខែឧសភា ឆ្នាំ២០០៨ ដែលជាធនាគារពាណិជ្ជទីមួយដែលគ្រប់គ្រងដោយជនជាតិជប៉ុន ក្នុងគោលបំណងចូលរួមអភិវឌ្ឍន៍ និងលើកស្ទួយប្រទេសកម្ពុជាតាមរយៈការផ្តល់នូវសេវាធនាគារសម្បូរបែប និងការវិនិយោគពីប្រទេសជប៉ុន។ ទស្សនៈវិស័យរបស់គាត់ គឺជួយគាំទ្រប្រជាជនកម្ពុជាដែលខិតខំចូលរួម ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជា ក្នុងស្មារតីប្រកួតប្រជែងដោយមិនផ្តេកផ្តួល ឬទទួលយកនូវស្ថានភាពបច្ចុប្បន្ននោះឡើយ។ ដើម្បីគាំទ្រឱ្យពេញលេញដល់ប្រជាជនកម្ពុជា ម៉ារ៉ូហាន់ ធនាគារជប៉ុនជាធនាគារពាណិជ្ជទីមួយដែលផ្តល់កម្ចីមិនមានទ្រព្យបញ្ចាំដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

ឱកាសបានលេចឡើងក្នុងខែធ្នូ ឆ្នាំ២០១២ ដែលអាចអនុញ្ញាតិឱ្យ ម៉ារ៉ូហាន់ ធនាគារជប៉ុន ភីអិលស៊ី មានលទ្ធភាពទិញយកភាគហ៊ុនរបស់ ស្ថាបនា លីមីតធីត ដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខគេក្នុងប្រទេសកម្ពុជា។ ស្ថាបនា លីមីតធីត ត្រូវបានបង្កើតឡើងដំបូងក្នុងនាមជា អង្គការក្រៅរដ្ឋាភិបាល (NGO) ក្នុងឆ្នាំ១៩៩៥ ហើយក្នុងពេលដែល ម៉ារ៉ូហាន់ ធនាគារជប៉ុន ទិញយកភាគហ៊ុនរបស់ស្ថាបនា ដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលអាចផ្តល់សេវាកម្ចីដល់ប្រជាជន ដែលមានចំណូលទាបនៅទូទាំងប្រទេសជាមួយនឹងការចូលរួមអភិវឌ្ឍន៍ និងលើកស្ទួយសេដ្ឋកិច្ចប្រទេសកម្ពុជា តាមរយៈសាខាចំនួន ១៤០ និងការិយាល័យផ្តល់សេវារបស់ខ្លួនជាច្រើនផ្សេងទៀតនៅទូទាំងប្រទេស។

ម៉ារ៉ូហាន់ ធនាគារជប៉ុន បានកំពុងផ្តោតសំខាន់លើការផ្តល់ផលិតផល និងសេវាធនាគារពាណិជ្ជដែលមានគោលបំណងពង្រីកប្រតិបត្តិការរបស់ខ្លួនទូរទាំងប្រទេស។ ជាមួយគ្នានេះដែរ ស្ថាបនា លីមីតធីត បានកំពុងផ្តោតសំខាន់លើសេវា និងផលិតផលមីក្រូហិរញ្ញវត្ថុទៅប្រជាជនដែលមានចំណូលទាបនៅទូរទាំងប្រទេស ដោយមានគោលបំណងក្លាយជាធនាគារពាណិជ្ជពេញលេញ។ លោកបណ្ឌិត Han Chang-Woo ប្រធានក្រុមប្រឹក្សាភិបាលបាន យល់ឃើញពីភាពស្រដៀងគ្នានៃសក្តានុពល និងគោលដៅរួមរបស់ម៉ារ៉ូហាន់ ធនាគារជប៉ុន និងស្ថាបនា លីមីតធីត ដែលអាចបំពេញឱ្យគ្នាទៅវិញទៅមកបាន ក៏លោកបានសម្រេចចិត្តធ្វើការរួមបញ្ចូលគ្នារវាងស្ថាប័នទាំងពីរដើម្បីកម្លាយខ្លួនជា ធនាគារពាណិជ្ជថ្មីមួយ។

អាស្រ័យដោយការរួមបញ្ចូលគ្នារវាងគ្រឹះស្ថានហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ពុំធ្លាប់មានប្រវត្តិពីមុនមក និងឆ្លងកាត់ការពិគ្រោះយោលបល់ជាច្រើនជាមួយ ធនាគារជាតិនៃកម្ពុជា និងស្ថាប័នរបស់រដ្ឋាភិបាលដែលពាក់ព័ន្ធ ធនាគារ ស្ថាបនា ភីអិលស៊ី ត្រូវបានបង្កើតឡើងដោយជោគជ័យក្នុងខែ មេសា ឆ្នាំ២០១៦ ជាមួយនឹងដើមទុនចុះបញ្ជី ១២០ លានដុល្លារសហរដ្ឋអាមេរិក មានសាខាចំនួន ១៦០ មានម៉ាស៊ីនអេធីអឹម ៧៣ និងបុគ្គលិកចំនួន ៣៤៥៨ នាក់។ ធនាគារពាណិជ្ជដែលបានរួមបញ្ចូលគ្នាថ្មី បានបង្កើតឡើងដើម្បីផ្តល់សេវាកម្មធនាគារប្រកបដោយភាពជឿជាក់ក្នុងនាមជាធនាគាររបស់ប្រជាជនក្នុងព្រះរាជាណាចក្រកម្ពុជានិងបំពាក់សក្តានុពលដល់សហគ្រិន ព្រមទាំងបង្កើតឱ្យមានឱកាសការងារដើម្បីបង្កើតអាជីវកម្ម និងលើកកំពស់ជីវភាពរស់នៅរបស់ពួកគេតាមរយៈការទទួលយកបាននូវសេវាកម្មហិរញ្ញវត្ថុដែលមានស្ថេរភាព។

ទិសដៅរបស់លោកបណ្ឌិត Han Chang-Woo ប្រធានក្រុមប្រឹក្សាភិបាល មានភាពច្បាស់លាស់គឺ «យើងនឹងបន្តលើកតម្កើនកម្រិតនៃការពេញចិត្តរបស់អតិថិជន និងពង្រីកអាជីវកម្មរបស់ពួកយើងជាមួយនឹងគំនិតឆ្នៃប្រឌិត និងស្មារតីជាអ្នកដឹកនាំ។ យើងមានគោលបំណងក្លាយជាធនាគារពាណិជ្ជឈានមុនគេក្នុងប្រទេសកម្ពុជា»។

បច្ចុប្បន្នធនាគារស្ថាបនា គឺជាធនាគារពាណិជ្ជឈានមុខគេនៅកម្ពុជា ដែលមានទ្រព្យសកម្មសរុបជាង ២.៤៤លានពាន់ដុល្លារអាមេរិក និងមានបុគ្គលិកបម្រើការជាង៤,០០០នាក់។ យើងមានបណ្តាលសាខាយ៉ាងទូលំទូលាយនៅទូទាំងប្រទេស ដែលក្នុងនោះមានសាខាច្រើនជាង ១៧០សាខា ផ្សារធនាគារស្ថាបនាព្រៃមៀម ចំនួន ៣ នឹងម៉ាស៊ីនអេធីអឹមជាង ២៥០ គ្រឿង ដែលមានសមត្ថភាពជានានៅលំហូចរន្តសាច់ប្រាក់យើងដល់សេវាធនាគារយ៉ាងពេញលេញ ដូចជា ប្រាប់បញ្ញើ ប្រាក់កម្ចី iBanking សេវាធនាគារចល័ត ប័ណ្ណឥណពន្ធ និងប័ណ្ណឥណទាន ការផ្ទេរប្រាក់ក្នុងនិងក្រៅប្រទេស Western Union ហិរញ្ញប្បទានពាណិជ្ជកម្ម និងសេវាកម្មជាច្រើនទៀត។ យើងក៏ផ្តល់ជូនផងដែរនៅសេវាកម្មប្រមូលពន្ធ និងទូទាត់ថ្លៃសេវាសាធារណៈជាមួយក្រសួងសាធារណការ និងដឹកជញ្ជូននិងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ យើងក៏សហការផងដែរជាមួយអ្នកផ្តល់សេវាទូទាត់ចល័តដូចជា Wing pay, True money ,Ly Hour Veluy ,eMoney និងBakong ដើម្បីបន្ថែមភាពងាយស្រួលដល់អតិថិជនរបស់យើង។ ភាពជាដៃគូរបស់យើងជាមួយក្រុមហ៊ុន ក្រេដឌីត ប្យូរ៉ូ(ខេមបូឌា)ខូអិលធីឌី (CBC) ផ្តល់ភាពងាយស្រួលដល់អតិថិជនរបស់យើង ក្នុងការត្រួតពិនិត្យស្ថានភាពហិរញ្ញវត្ថុតាមរយៈកម្មវិធីស្ថាបនា ម៉ូបាល[1]។

**៣.១.២ ចក្ខុវិស័យ បេសកម្ម គុណតម្លៃ របស់ធនាគារស្ថាបនា**

**ក. ចក្ខុវិស័យ**

ជាធនាគារដែលឈានមុខគេ និងគួរឱ្យទុកចិត្តបំផុតក្នុងការផ្តល់សេវាកម្មធនាគារពេញលេញនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ខ. បេសកម្ម**

ជួយលើកកម្ពស់អាជីវកម្ម និងជីវភាពរស់នៅរបស់ប្រជាជន តាមរយៈការផ្តល់សេវាកម្មធនាគារពេញលេញ ដោយប្រើបច្ចេកវិទ្យាទំនើបនៅទូទាំងប្រទេស និងរួមចំណែកដល់ការអភិវឌ្ឍប្រទេសកម្ពុជា ប្រកបដោយ ចីរភាព។

**គ. គុណតម្លៃ**

យើងបានណែនាំគុណតម្លៃថ្មីរបស់យើងនៅដើមឆ្នាំ2021 តាមរយៈផែនការយុទ្ធសាស្ត្រទំនាក់ទំនងដ៏ទូលំទូលាយ។ សព្វថ្ងៃនេះគ្រប់បុគ្គលិក របស់យើងបានសម្តែងនូវការពេញចិត្ត និងប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវគុណតម្លៃថ្មី។ រាល់សកម្មភាពរបស់យើងសម្រាប់ឆ្នាំ2021 នៅតែមានភាពរឹងមាំដែលសមស្របតាមបរិបទដ៏លំបាកនាឆ្នាំនេះ។ ការចែករំលែកចំណេះដឹងថ្មីៗ រៀងរាល់ការជួបជុំនៅពេលព្រឹក ការដាក់បង្ហាញអំពីគុណតម្លៃតាមអេក្រង់កុំព្យូទ័រប័ណ្ណផលិតផលសេវាកម្មតាមសាខានីមួយៗនិងទីស្នាក់ការកណ្តាលរួមទាំងការវាយតម្លៃការងារប្រចាំឆ្នាំ ត្រូវបានដាក់បញ្ចូលដើម្បីធានាបាន នូវការអនុវត្តយ៉ាងខ្ជាប់ខ្ជួនពីបុគ្គលិកទាំងអស់[2]។

[1] https://www.sathapana.com.kh/kh/about-us 25/02/2024
[2] https://www.nbc.gov.kh/ 25/02/2024

### ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច របស់ធនាគារស្ថាបនា

### ក. រចនាសម្ព័ន្ធគ្រប់គ្រង



### ខ. តួនាទីគណៈគ្រប់គ្រង

**បណ្ឌិត HAN CHANG-WOO**

**ប្រធានក្រុមប្រឹក្សាភិបាល**

លោកបណ្ឌិត HAN CHANG-WOO ជាស្ថាបនិក និងជាប្រធានក្រុមហ៊ុន MARUHAN Corporation ក្នុងប្រទេសជប៉ុនដែលកំពុងធ្វើការផ្គត់ផ្គង់ និងរៀបចំសម្ភារកម្សាន្តជាច្រើនប្រភេទដូចជា៖ទីលានវាយកូនហ្គោលទីលានហាត់វាយកូនហ្គោល កន្លែងបោះបូលីងមជ្ឈមណ្ឌលហ្គេម ភោជនីយដ្ឋាននិង PachinkoParlors (Pinballរបស់ជប៉ុន )។លោកបណ្ឌិត បានបង្កើតក្រុមហ៊ុន MARUHAN Corporationក្នុងឆ្នាំ១៩៥៧ និងបានធ្វើឱ្យអាជីវកម្មមួយនេះមានការរីកចម្រើនយ៉ាងលឿនដែលបាទទួលចំណូលក្នុងការលក់សរុបជាង២៥ពាន់លានដុល្លារក្នុងមួយឆ្នាំ។ក្រុមហ៊ុនMARUHANCorporation ត្រូវបានស្គាល់ថាជាក្រុមហ៊ុនឈានមុខគេក្នុងវិស័យឧស្សាហកម្មក្នុងប្រទេសជប៉ុន។ ជោគជ័យនៃការរីកចម្រើនផ្នែកអាជីវកម្មរបស់ក្រុមហ៊ុន គឺកើតចេញពីការប្ដេជ្ញាចិត្តក្នុងការប្រកួតប្រជែងខ្ពស់របស់លោកបណ្ឌិត HAN និងជំនឿចិត្តដ៏រឹងមាំក្នុងការបំពេញតាមតម្រូវចិត្តរបស់អតិថិជន។ បច្ចុប្បន្ន លោកបណ្ឌិត កំពុងចូលរួមយ៉ាងសកម្មជាមួយសមាគមមួយចំនួនក្នុងនាមជាទីប្រឹក្សាកិត្តិយសនៃមូលនិធិវប្បធម៌ Han Chang-Woo Tetsu ប្រធានសមាគម Kyoto UNESCOAssociation ប្រធានសមាគម United Nations Association of Japan Kyoto Headquarters ប្រធាន Tokyo Philharmonic ប្រធានក្រុមប្រឹក្សាភិបាល World Federation of Korean Chambers of Commerce and Industry និងទីប្រឹក្សាកិត្តិយសនៃ Central Association of Japan-Korea

Friendship Societies ។ចាប់តាំងពីខែមិថុនាឆ្នាំ២០២៣ លោកជាអភិបាលតំណាង និងជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនTaiheiyoClub,Inc.ដែលជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនMARUHAN Corporation ទទួលបន្ទុកលើការគ្រប់គ្រងទីលានវាយកូនហ្គោលចំនួន១៨នៅប្រទេសជប៉ុន និងជាទីកន្លែងសម្រាប់ប្រារព្ធការប្រកួតជើងឯកវាយកូនហ្គោលលំដាប់ពិភពលោកជាប្រចាំ។ លោកគឺបានទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចនយោបាយពីសាកលវិទ្យាល័យHoseiនៅឆ្នាំ១៩៥៣។

**លោក HAN KEN**

**អនុប្រធានក្រុមប្រឹក្សាភិបាល**

លោក HANKENបានបម្រើការជាមួយក្រុមហ៊ុនMARUHANCorporation ក្នុងឆ្នាំ២០០០ បន្ទាប់ពីលោកបានធ្វើការនៅក្រុមហ៊ុនមូលធនប័ត្រNomuraតាំងពីឆ្នាំ១៩៩៨។ នៅឆ្នាំ២០០៧ លោកត្រូវបានចាត់តាំងជាអភិបាលនៃក្រុមហ៊ុន MARUHAN Corporation ហើយនៅឆ្នាំ២០១៤ ជាអភិបាលប្រតិបត្តិ។ នៅឆ្នាំ២០២០ លោកត្រូវបានចាត់តាំងជាតំណាងអភិបាលប្រចាំតំបន់។ នៅឆ្នាំ២០២១ លោកត្រូវបានចាត់តាំងជាប្រធានក្រុមហ៊ុនហិរញ្ញវត្ថុ នៃក្រុមហ៊ុន MARUHANCorporation។ លោកក៏មានតួនាទីអភិបាលផ្នែកគ្រប់គ្រង និងជាប្រធាននាយកប្រតិបត្តិរបស់ក្រុមហ៊ុន MARUHAN Investment Asia Pte. Ltd ដែលមានស្នាក់ការកណ្តាលស្ថិតនៅក្នុងប្រទេសសិង្ហបុរី។ លោកគ្រប់គ្រងក្រុមហ៊ុនបុត្រសម្ព័ន្ធហិរញ្ញវត្ថុដូចជា ធនាគារស្ថាបនា ភីអិលស៊ី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនាលីមីតធីត នៅប្រទេសមីយ៉ាន់ម៉ា និងម៉ារ៉ូហាន់ ធនាគារជប៉ុននៅប្រទេសឡាវ។ នៅខែមិថុនា ឆ្នាំ២០២៣ លោកត្រូវបានតែងតាំងជាអភិបាលនៃក្រុមហ៊ុន Taiheiyo Club, Inc. ដែលជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន MARUHAN Corporation ទទួលបន្ទុកលើការគ្រប់គ្រងទីលានវាយកូនហ្គោលចំនួន១៨ នៅប្រទេសជប៉ុន និងជាទីកន្លែងសម្រាប់ប្រារព្ធការប្រកួតជើងឯកវាយកូនហ្គោលលំដាប់ពិភពលោកជាប្រចាំ។ លោកក៏បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកច្បាប់ ពីសាកលវិទ្យាល័យDOSHISHAនៅឆ្នាំ១៩៩៧។

**លោក IWASA TOMOYUKI**

**អភិបាល**

លោក IWASA TOMOYUKI មានបទពិសោធន៍ជាង ៣០ឆ្នាំ ក្នុងវិស័យធនាគារចាប់តាំងពីលោកបានចាប់ផ្តើមអាជីពក្នុងឆ្នាំ១៩៨៩ នៅធនាគារ Mizuho Bank Ltd. ក្នុងប្រទេសជប៉ុន។ លោកបានកាន់មុខតំណែង និងធ្វើការជាច្រើននៅក្នុងវិស័យធនាគារសាជីវកម្មដោយរួមមាន៖ ការផ្សព្វផ្សាយពាណិជ្ជកម្ម ការធ្វើផែនការយុទ្ធសាស្ត្រការគ្រប់គ្រងហានិភ័យ និងឥណទានទាំងសម្រាប់ទីផ្សារក្នុងស្រុក និងក្រៅស្រុក។ បន្ទាប់ពីអាជីពចុងក្រោយរបស់លោកនៅធនាគារMizuho ក្នុងតួនាទីជាអគ្គនាយករងនៃនាយកដ្ឋានឥណទានអាមេរិកនៅទីក្រុងញូវយ៉ក លោកបានចូលរួមជាមួយ MARUHAN Corporation ក្នុងខែសីហា ឆ្នាំ២០១៩ ដែលជាម្ចាស់ភាគហ៊ុនរបស់ ធនាគារស្ថាបនា ភីអិលស៊ី។ បច្ចុប្បន្ននេះ លោកមានតួនាទីជាមន្រ្តីសាជីវកម្មនៃក្រុមហ៊ុនហិរញ្ញវត្ថុ និងជាអ្នកគ្រប់គ្រងទូទៅនៃនាយកដ្ឋានអាជីវកម្មធនាគារ និងនាយកដ្ឋានផែនការយុទ្ធសាស្ត្រ។ លោក Iwasaបានទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យ Vanderbilt (សហរដ្ឋអាមេរិក) ក្នុងឆ្នាំ២០០០ និងបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យTokyo(ប្រទេសជប៉ុន) ក្នុងឆ្នាំ១៩៨៩។

**ឯកឧត្តម SHINOHARA KATSUHIRO**

**អភិបាលឯករាជ្យ**

ឯកឧត្តម SHINOHARA KATSUHIROធ្លាប់មានប្រវត្តិរស់នៅប្រទេសកម្ពុជាជាង ៥០ឆ្នាំកន្លងមកហើយ។ នៅឆ្នាំ១៩៦៧ គាត់បានមកដល់ប្រទេសកម្ពុជាលើកដំបូងក្នុងនាមជាមន្ត្រីការទូតរបស់ជប៉ុន និងបានចំណាយពេល២ឆ្នាំដំបូងរស់នៅក្នុងវត្តឧណ្ណាលោម ក្នុងរាជធានីភ្នំពេញដែលក្នុងនោះលោកបានចំណាយពេល៧ខែបួសជាព្រះសង្ឃ ដើម្បីសិក្សាភាសានិងវប្បធម៌ខ្មែរមុនពេលចូលកាន់មុខដំណែងជាមន្ត្រីលេខានៅស្ថានទូតជប៉ុនក្នុងប្រទេសកម្ពុជា។ បន្ទាប់ពីឯកឧត្តមបានវិលត្រឡប់មកកាន់ប្រទេសកម្ពុជាក្នុងនាមជាអគ្គទីប្រឹក្សាស្ថានទូតជប៉ុន (ពីឆ្នាំ១៩៩១ដល់ឆ្នាំ១៩៩៤ និងពីឆ្នាំ២០០១ដល់ឆ្នាំ២០០៤) ឯកឧត្តមបានបង្កើតចំណងមិត្តភាពជាមួយនឹងប្រទេសកម្ពុជាយ៉ាងរឹងមាំ ក្នុងតួនាទីជាឯកអគ្គរាជទូតជប៉ុនប្រចាំប្រទេសកម្ពុជាចាប់ពីឆ្នាំ២០០៧ រហូតដល់ឆ្នាំ២០០៩។ ចាប់ពីខែធ្នូ ឆ្នាំ២០១២ មក ឯកឧត្តម គឺជាអភិបាលឯករាជ្យរបស់ធនាគារស្ថាបនា ហើយលោកក៏ជាសមាជិកគណៈកម្មការកម្រិតក្រុមប្រឹក្សាភិបាល។ បច្ចុប្បន្ន លោកជាប្រធានតំណាងនៃអង្គការ NGO មូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា(CIESF )នៃប្រទេសជប៉ុន ដែលមានមានទីតាំងនៅរាជធានីភ្នំពេញ។

**ឯកឧត្តម គិម វ៉ាដា**

**អភិបាលឯករាជ្យ**

ឯកឧត្តម គិម វ៉ាដា មានបទពិសោធន៍ការងាររយៈពេលជាង៣៧ ឆ្នាំនៅធនាគារជាតិនៃកម្ពុជាដោយចាប់ផ្តើមពីតំណែងជាប្រធានការិយាល័យ នៅសាខាខេត្តកណ្តាលរបស់ធនាគារជាតិ នៃកម្ពុជា រហូតក្លាយជាអគ្គនាយកនៃអគ្គនាយកដ្ឋានត្រួតពិនិត្យនៃធនាគារជាតិនៃកម្ពុជា។ ក្នុងអំឡុងពេលបំពេញការងារនៅ ធនាគារជាតិ ឯកឧត្តមបានទទួលបន្ទុកនិង មានតួនាទីជាថ្នាក់ដឹកនាំជាន់ខ្ពស់ជាច្រើនជាមួយនឹងបទពិសោធន៍ទូលំទូលាយក្នុងវិស័យធនាគារដោយរួមបញ្ចូលទាំងផ្នែកគ្រប់គ្រងហានិភ័យ (ហានិភ័យទីផ្សារ ហានិភ័យឥណទា ហានិភ័យសន្ទនីយភាព និងហានិភ័យប្រតិបត្តិការជាដើម) អភិបាលកិច្ច និងយុទ្ធសាស្ត្រអាជីវកម្ម។ ឯកឧត្តមបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំប្រព័ន្ធធនាគារនៅកម្ពុជាឡើងវិញយ៉ាងជោគជ័យក្នុងអំឡុងទសវត្សឆ្នាំ២០០០ ក្នុងការបង្កើតឱ្យមានប្រព័ន្ធធនាគារមួយដែលមានលក្ខណៈប្រកួតប្រជែងនិងប្រកបដោយសុវត្ថិភាពក្រោមការត្រួតពិនិត្យនិងគ្រប់គ្រងបានយ៉ាងល្អ ព្រមទាំងបានបង្កើតឱ្យមានការកេណ្ឌប្រមូលប្រាក់បញ្ញើយ៉ាងមានប្រសិទ្ធភាពសម្រាប់ផ្តល់ហិរញ្ញទាន ដើម្បីជម្រុញកំណើនសេដ្ឋកិច្ចកម្ពុជា។ ឯកឧត្តម គិម វ៉ាដា ទទួលបានបរិញ្ញាបត្រផ្នែកច្បាប់ក្នុងឆ្នាំ ១៩៧៥ បរិញ្ញាបត្រផ្នែកធនាគារ ក្នុងឆ្នាំ១៩៨៥ និងអនុបណ្ឌិតផ្នែកគ្រប់គ្រងធុរកិច្ច ជំនាញហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី នៅឆ្នាំ ២០០៣។ ឯកឧត្តមធ្លាប់ធ្វើជាសាស្ត្រាចារ្យ និងជាវាគ្មិននៅសាកលវិទ្យាល័យល្បីៗមួយចំនួន នៅក្នុងប្រទេសកម្ពុជា។ លើសពីនេះ ក្នុងអំឡុងពេល១០ឆ្នាំចុងក្រោយនេះ លោកបានចូលរួមយ៉ាងសកម្ម ក្នុងនាមជាវាគ្មិនក្នុងសន្និសីទសិក្ខាសាលាជាតិ និងអន្តរជាតិជាច្រើនដែលទាក់ទងនឹងក្របខណ្ឌបទប្បញ្ញត្តិច្បាប់ការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ ព្រមទាំងសេវាកម្មធនាគារចល័តនិងបរិយាប័ន្នហិរញ្ញវត្ថុ។ ចំពោះការងារអន្តរជាតិ លោកបានទទួលបន្ទុក ជាប្រធានក្រុមប្រឹក្សាភិបាលនៃសមាគមឥណទានកសិកម្ម ហើយនិងជនបទប្រចាំ

តំបន់អាស៊ីប៉ាស៊ីហ្វិក (APRACA) ពីខែកក្កដា ឆ្នាំ២០១២ ដល់ខែមិថុនា ឆ្នាំ២០១៤ និងជាសមាជិកប្រតិបត្តិ នៃសហព័ន្ធបរិយាប័ន្នហិរញ្ញវត្ថុ (AFI) ពីខែមករា ឆ្នាំ២០១៥ ដល់ខែមិថុនា ឆ្នាំ២០១៧ ផងដែរ។

**លោក QUOCANH NYUGENLE**

**អភិបាលឯករាជ្យ**

លោក QuocAnh NguyenLeមានបទពិសោធន៍ជាង30 ឆ្នាំ លើវិស្វកម្ម បច្ចេកវិទ្យា និងការគ្រប់គ្រងអាជីវកម្មតាំងពីឆ្នាំ1988 ក្នុងនាមជាវិស្វករនុយក្លេអ៊ែរនៅក្រុមហ៊ុនPG&E នៅទីក្រុងSan Franciscoសហរដ្ឋអាមេរិក។ ក្រោយមកលោកបានកាន់មុខតំណែងជាច្រើនទៀតដូចជា៖ ជាវិស្វករស្រាវជ្រាវនៅមន្ទីរពិសោធន៍ជាតិArgonne នៅទីក្រុងChicago សហរដ្ឋអាមេរិកជាទីប្រឹក្សានៅក្រុមហ៊ុនឈ្មោះMcKinsey &Co.Ltd នៅទីក្រុងChicago សហរដ្ឋអាមេរិកជានាយកផ្នែកQuantitativeTrading នៅFortress Investment Group នៅទីក្រុង New York សហរដ្ឋអាមេរិក ជានាយកផ្នែកផែនការយុទ្ធសាស្ត្រនៅ ក្រុមហ៊ុន Wells Fargo នៅទីក្រុង San Francisco សហរដ្ឋអាមេរិក និងជានាយកក្រុមហ៊ុន T-Mobile US នៅទីក្រុង Seattle សហរដ្ឋអាមេរិក។ ថ្មីៗនេះលោកគឺជាប្រធាននាយកប្រតិបត្តិ នៃធនាគារ Techcombank នៅទីក្រុងហាណូយ ប្រទេសវៀតណាម។ លោកNguyenLe បានទទួលសញ្ញាប័ត្របណ្ឌិតផ្នែកទស្សនវិជ្ជាMSនិងBS ផ្នែកវិស្វកម្មនុយក្លេអ៊ែរពីសាកលវិទ្យាល័យ Purdue នៅ West Lafayette សហរដ្ឋអាមេរិក និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ចពីរដ្ឋ California East Bay សហរដ្ឋអាមេរិក។

**គ. ភារកិច្ចគណៈគ្រប់គ្រង**

**លោក IWASA TOMOYUKI**

**ប្រធាននាយកប្រតិបត្តិស្តីទី**

បន្ទុប្បន្ននេះ លោក IWASA TOMOYUKI គឺជាប្រធាននាយកប្រតិបត្តិស្តីទី នៃធនាគារ ស្ថាបនា។ លោកមានបទពិសោធន៍ជាង ៣០ឆ្នាំ ក្នុងវិស័យធនាគារចាប់តាំងពីលោកបានចាប់ផ្តើមអាជីពក្នុងឆ្នាំ១៩៨៩ នៅធនាគារ Mizuho Bank Ltd. ក្នុងប្រទេសជប៉ុន។ លោកបានកាន់មុខតំណែង និងធ្វើការជាច្រើននៅក្នុងវិស័យធនាគារសាជីវកម្មដោយរួមមាន៖ការផ្សព្វផ្សាយពាណិជ្ជកម្ម ការធ្វើផែនការយុទ្ធសាស្ត្រការគ្រប់គ្រងហានិភ័យ និងឥណទានទាំងសម្រាប់ទីផ្សារក្នុងស្រុក និងក្រៅស្រុក។ បន្ទាប់ពីអាជីពចុងក្រោយរបស់លោកនៅធនាគារ Mizuhoក្នុងតួនាទីជាអគ្គនាយករងនាយកដ្ឋានឥណទានអាមេរិកនៅទីក្រុងញូវយ៉កលោកបានចូលរួមជាមួយMARUHAN Corporation ក្នុងខែសីហា ឆ្នាំ២០១៩ ដែលជាម្ចាស់ភាគហ៊ុនរបស់ ធនាគារស្ថាបនា ភីអិលស៊ី និងហើយបច្ចុប្បន្ននេះលោកក៏មានតួនាទីជាមន្ត្រីសាជីវកម្ម។

**លោក ដេវីដ វីឆាត ថូម៉ាស**

**អនុប្រធាននាយកប្រតិបត្តិ**

លោក ថូម៉ាស មានបទពិសោធន៍ការងារជាង៣០ឆ្នាំនៅអាស៊ីប៉ាស៊ីហ្វិក។ មុនពេលចូលបម្រើការងារនៅធនាគារស្ថាបនា លោកជានាយកប្រតិបត្តិហានិភ័យនៅChina Development Financial Group(តៃវ៉ាន់)។ បន្ថែមពីលើនេះលោកក៏ធ្លាប់ជានាយកប្រតិបត្តិហានិភ័យក្នុងក្រុមហ៊ុCIMBGroup នាយកប្រតិបត្តិហានិភ័យនៅអាស៊ីប៉ាស៊ីហ្វិកសម្រាប់ធនាគារ Royal Bank of Scotlandនិងជានាយកប្រតិបត្តិ ប្រតិបត្តិការឥណទាននៅអាស៊ីប៉ាស៊ីហ្វិកសម្រាប់ធនាគារ Bank of America។ លោកក៏ធ្លាប់ជាសមាជិកក្រុមប្រឹក្សាភិបាលរបស់

ធនាគារ KGI Bank(តៃវ៉ាន់)និងធនាគារ PT Bank CIMB Niaga Tbkផងដែរ។ លោកមានបទពិសោធន៍កាន់មុខតំណែងជាថ្នាក់គ្រប់គ្រងជាន់ខ្ពស់ជាច្រើនទាក់ទងទៅនឹងការគ្រប់គ្រងហានិភ័យ នៅតាមបណ្ដាប្រទេសផ្សេងៗដូចជា៖ ប្រទេសសិង្ហបុរី ហុងកុង ថៃ តៃវ៉ាន់ និងម៉ាឡេស៊ី។ លោក ថូម៉ាស ធ្លាប់ទទួលបានពានរង្វាន់ជាមន្ត្រីគ្រប់គ្រងហានិភ័យធនាគារនៅអាស៊ីឆ្នើមប្រចាំឆ្នាំ២០១៨។

**លោក គូរ៉ូគី កាន់ជី**

**អនុប្រធាននាយកប្រតិបត្តិ**

លោក គូរ៉ូគី កាន់ជី មានបទពិសោធន៍ជាង៣០ឆ្នាំ លើផ្នែកធនាគារពាណិជ្ជតាំងពីលោកចាប់ផ្ដើមការងារនៅឆ្នាំ១៩៨៩ នៅធនាគារSumitomo លីមីតធីត (ក្រោយមកត្រូវប្ដូរឈ្មោះទៅជាធនាគារ Sumitomo Mitsui ឬ SMBC) នៅប្រទេសជប៉ុន។ នៅធនាគារ SMBC លោកគឺ ជាប្រធានផ្នែកគម្រោងនៃធនាគារ PT Sumitomo Mitsuiប្រទេសឥណ្ឌូនេស៊ីចាប់ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០៣។ លោកក៏ជាអនុប្រធានគ្រប់គ្រងទូទៅនៃធនាគារ Eximbank ប្រទេសវៀតណាម ដែលជាសមាជិកធនាគារSMBC ប្រចាំប្រទេសវៀតណាមចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៥។ នាខែឧសភា ឆ្នាំ២០១៨លោកបានចាកចេញពីធនាគារSMBC ហើយចូលមកបម្រើការនៅMARUHANCorporation ដែលជាម្ចាស់ភាគហ៊ុនរបស់ ធនាគារស្ថាបនា។ ក្នុងខែធ្នូ ឆ្នាំ២០២១ លោកក៏ចូលមកបម្រើការក្នុងតំណែងជាអនុប្រធានប្រតិបត្តិនៅធនាគារស្ថាបនា។ លោកគូរ៉ូគីទទួលបានបរិញ្ញាបត្រផ្នែកសិល្បៈនៃការសិក្សាឥណ្ឌូចិនពីសាកលវិទ្យាល័យTokyoនៅឆ្នាំ១៩៨៩។

**លោក ហ្គាញ៉ុង ហ្សង់ព្យែរ ចូសែប អង់ជ្រេ**

**អនុប្រធាននាយកប្រតិបត្តិ**

លោក ហ្គាញ៉ុង ហ្សង់ព្យែរ ចូសែប អង់ជ្រេ គឺជាអនុប្រធានប្រតិបត្តិនៅ ធនាគារស្ថាបនា ជាមួយនឹងបទពិសោធន៍ជាង ២០ឆ្នាំលើការដឹកនាំអង្គភាពនៅក្នុងវិស័យFintechនិងប្រព័ន្ធទូទាត់ប្រាក់។ មុននឹងលោកចូលមកបម្រើការនៅធនាគារស្ថាបនា លោកធ្លាប់ជាអគ្គនាយកនៃ beFinancial នៅប្រទេសវៀតណាម និងជាអគ្គនាយកនៃ Eko-Pay។ កាលពីលោកនៅបម្រើការនៅមុខតំណែងមុនៗ លោកបានដឹកនាំឱ្យមានការអភិវឌ្ឍការធ្វើអនុកលកម្ម និងការប្រតិបត្តិនៃដំណោះស្រាយកម្មសិទ្ធិ នៅក្នុងធនាគារជាច្រើន និងផ្នែកប័ណ្ណដូចជា ប័ណ្ណវីសា និងម៉ាស្ទ័រ។ ច្រើនឆ្នាំកន្លងមកនេះ លោក ហ្គាញ៉ុង បាននាំការលក់នៃប្រព័ន្ធ POS Loyalty Program ការសហការដៃគូផ្សព្វផ្សាយប័ណ្ណ ដំណោះស្រាយហិរញ្ញវត្ថុឌីជីថល និងផលិតផលធនាគារបែបឌីជីថលនៅទូទាំងតំបន់អាមេរិកខាងជើង សហភាពអឺរ៉ុប និងអាស៊ីប៉ាស៊ីហ្វិក។ ជាមួយនឹងចំណេះដឹងដ៏ជ្រៅជ្រះនៃសកម្មភាពអភិវឌ្ឍពាណិជ្ជកម្ម ដំណោះស្រាយទូទាត់ប្រាក់ ដំណើរការហេដ្ឋរចនាសម្ព័ន្ធ និងការបញ្ចេញប័ណ្ណ លោកក៏មានតួនាទីដឹងនាំ និងគ្រប់គ្រងលើផ្នែកប្រតិបត្តិការធនាគារ ផ្នែកព័ត៌មានវិទ្យា និងផលិតផលឌីជីថល។ លើសពីនេះទៅទៀត លោកក៏មានតួនាទីដឹងនាំផ្នែកអភិវឌ្ឍដៃគូអាជីវកម្ម ខណៈលោកកំពុងបង្វឹក និងបង្កើតក្រុមការងារពូកែៗនិងមានទេពកោសល្យនៅធនាគារស្ថាបនា។

**កញ្ញា ជេននីហ្វឺលី**

**នាយិកាប្រត្តិបត្តិអភិវឌ្ឍន៍**

កញ្ញា ជេននីហ្វឺ លី ឆោវលីន ដែលជានាយិកាប្រតិបត្តិអភិវឌ្ឍន៍នៅ ធនាគារស្ថាបនា គឺជាបុគ្គលម្នាក់ដែលស្រឡាញ់ផ្នែកឌីជីថលតាំងពីចូលបម្រើការដំបូងលើគម្រោងឌីជីថលនៅឆ្នាំ១៩៩៣ អស់រយៈពេល

២៦ឆ្នាំ កញ្ញាបានពង្រីកបទពិសោធន៍របស់ខ្លួនយ៉ាងទូលំទូលាយក្នុងវិស័យឌីជីថលដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាជាច្រើន។ កញ្ញាជេននីហ្វឺ បានធ្វើការជាអ្នកផ្តល់សេវាកម្មផ្នែកឌីជីថលសហគ្រិនបច្ចេកទេស ហើយបានជួយដល់ការរៀបចំបង្កើតឡើងនូវការពង្រឹងបច្ចេកវិទ្យា និងបានដឹកនាំគម្រោងឌីជីថល និងកិច្ចជំនួបនៅក្នុងក្រុមហ៊ុនទូរគមនាគមន៍។ ថ្មីៗនេះ កញ្ញាបានដឹកនាំផ្នែកព័ត៌មានវិទ្យា និងឌីជីថល ដើម្បីរៀបចំធនាគារថ្មី និងកែប្រែពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទៅជាធនាគារពាណិជ្ជពេញលេញ។ កញ្ញា ជេននីហ្វឺ ទទួលបានបរិញ្ញាបត្រផ្នែកទំនាក់ទំនងពីសាកលវិទ្យាល័យ Science Malaysia។

**លោក សៀង សេរី**

**នាយកប្រតិបត្តិ រដ្ឋបាល**

លោក សៀង សេរី មានបទពិសោធន៍ជាង ២៥ឆ្នាំ ជាមួយស្ថាប័នហិរញ្ញវត្ថុជាច្រើន និងក្រុមហ៊ុន FMCG អន្តរជាតិ។ មុនពេលលោកត្រលប់មកបម្រើការងារនៅធនាគារ ស្ថាបនា ភីអិលស៊ី ជានាយកប្រតិបត្តិរដ្ឋបាល នៅខែមករា ឆ្នាំ២០២៣ លោកត្រូវបានតែងតាំងជាប្រធាននាយកប្រតិបត្តិនៃធនាគារស្ថាបនា លីមីតធីត ក្នុងប្រទេសភូមា។ បន្ថែមពីលើនេះទៅទៀត លោកបានធ្លាប់បម្រើការងារនៅធនាគារ ជប៉ុន MARUHAN ក្នុងឆ្នាំ២០០៨ ជាប្រធានសាខា និងបានអភិវឌ្ឍអាជីពការងាររបស់លោកក្នុងតួនាទីផ្សេងៗជាច្រើនទៀតរួមមាន៖ ប្រធានសាខាស្នាក់ការកណ្តាល ប្រធានផ្នែកលក់ ប្រធានស្ថាប័នហិរញ្ញវត្ថុ នាយកប្រតិបត្តិរដ្ឋបាលនិងប្រធាននាយកប្រតិបត្តិ។

លោក សេរី បានបញ្ចប់បរិញ្ញាបត្រផ្នែកគ្រប់គ្រងពីសាកលវិទ្យាល័យ MAHARISHI Vedic ក្នុងឆ្នាំ១៩៩៧ និងអនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្មក្នុងឆ្នាំ២០០៨ពីសាកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី។ ក្នុងដំណើរអាជីពការងាររបស់លោក លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាតិ និងអន្តរជាតិជាច្រើនដែលទាក់ទងទៅនឹងធនាគារធុរកិច្ច។ លើសពីនេះទៅទៀត លោកត្រូវបានទទួលស្គាល់ជាសមាជិកក្រុមប្រឹក្សាភិបាលដែលមានវិជ្ជាជីវៈពីវិទ្យាស្ថាន MyanmarInstitute of Directors (MIoD) ក្នុងឆ្នាំ២០២០។

**លោក ស៊ឹយ ប៉ុណ្ណរតន៍**

**នាយកប្រតិបត្តិហិរញ្ញវត្ថុ**

លោក ស៊ឹយ ប៉ុណ្ណរតន៍ មានបទពិសោធន៍ជាង១៨ ឆ្នាំជាមួយក្រុមហ៊ុន និងគ្រឹះស្ថានហិរញ្ញវត្ថុជាច្រើន នៅក្នុងប្រទេសកម្ពុជា។ លោក ប៉ុណ្ណរតន៍ ចូលបម្រើការងារនៅ ធនាគារស្ថាបនា នៅខែតុលា ឆ្នាំ ២០១៧។មុននឹងចូលបម្រើការនៅធនាគារស្ថាបនា លោក គឺជាប្រធានទូទៅ ដែលគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និងព័ត៌មានវិទ្យានៅក្រុមហ៊ុនតូយ៉ូតា ប្រទេសកម្ពុជា។ លោកក៏ធ្លាប់ជានាយកប្រតិបត្តិហិរញ្ញវត្ថុ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា មុននឹងលោកត្រូវបានឡើង តំណែងទៅជាប្រធាននាយកប្រតិបត្តិនៅគ្រឹះស្ថានតែមួយ។ លោកប៉ុណ្ណរតន៍ មានជំនាញយ៉ាងស្ទាត់ជំនាញទាក់ទងទៅនឹងនៅគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិជាច្រើន និងមានបទពិសោធន៍ជាច្រើនឆ្នាំនៅក្នុងការគ្រប់គ្រងគម្រោងផ្សេងៗដូចជា ERP IT IFRS និងប្រព័ន្ធធនាគារស្នូល។ លោកត្រូវបានទទួលស្គាល់ជាអ្នកគ្រប់គ្រងគម្រោងដែលចេញដោយវិទ្យាស្ថានគ្រប់គ្រងគម្រោង ដែលមានទីតាំងនៅសហរដ្ឋអាមេរិក។ លើសពីនោះ លោកគឺជា Chartered Banker (CB) ដែលទទួលស្គាល់ដោយ វិទ្យាស្ថាន Chartered Banker នៅចក្រភពអង់គ្លេស និងវិទ្យាស្ថាន Chartered Banker ប្រចាំអាស៊ីនៅប្រទេសម៉ាឡេស៊ី។ លោកក៏ជាសមាជិក FCCA នៃសមាគមគណនេយ្យករដែលទទួលបានអាជ្ញាប័ណ្ណផ្នែកគណនេយ្យ

(ACCA)នៅចក្រភពអង់គ្លេស។ លោកក៏ទទួលបានសញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែករដ្ឋបាលពាណិជ្ជកម្ម ពីសាលាពាណិជ្ជកម្ម Audencia ដែលស្ថិតនៅចំណោមសាលាពាណិជ្ជកម្មកំពូលនៅបារាំង និងទូទាំងសកលលោក។ បន្ថែមពីលើនេះទៅទៀត លោកក៏ទទួលបានវិញ្ញាបនបត្រឧត្តមភាពផ្នែកគ្រប់គ្រងពីសាលាពាណិជ្ជកម្ម Harvard នៅសហរដ្ឋអាមេរិក និងវិញ្ញាបនបត្រផ្នែកវិភាគអាជីវកម្មពីសាលា Columbia Business School។ លើសពីនេះទៅទៀត លោកក៏ជាសមាជិកនៃ Harvard Business Review Advisory Council ដែលជាសហគមន៍ស្រាវជ្រាវសម្រាប់អ្នកជំនាញអាជីវកម្ម។

**លោក ម៉េង វាសនា**

**នាយកប្រតិបត្តិហានិភ័យ**

លោក ម៉េង វាសនា មានបទពិសោធន៍ជាង១៦ឆ្នាំ នៅក្នុងវិស័យធនាគារ និងក្រុមហ៊ុនសវនកម្មអន្តរជាតិមួយ។ លោកធ្លាប់ជាប្រធានផ្នែកសវនកម្មនៅក្រុមហ៊ុនPricewaterhouseCoopers ក្នុងប្រទេសកម្ពុជា មុននឹងលោកបានចូលបម្រើការនៅ ម៉ារូហាន់ ធនាគារជប៉ុន នៅខែមេសា ឆ្នាំ២០១២ ក្នុងតំណែងជានាយកសវនកម្មផ្ទៃក្នុង និងបន្ទាប់មកកាន់តំណែងផ្សេងទៀតដូចជា ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យសាជីវកម្ម និងប្រធាននាយកដ្ឋានឥណទានមុនពេលការរួមបញ្ចូលគ្នារវាង ម៉ារូហាន់ ធនាគារ ជប៉ុន និង ស្ថាបនា លីមីតធីត ក្លាយទៅជាធនាគារពាណិជ្ជ កាលពីខែមេសា ឆ្នាំ២០១៦។ លោកក៏បានបន្តបម្រើការជាប្រធាននាយកដ្ឋានឥណទានអាជីវកម្ម រហូតដល់លោកត្រូវបានតែងតាំងជានាយកប្រតិបត្តិហានិភ័យ នៅខែមេសា ឆ្នាំ២០២០។លោក វាសនា ទទួលបរិញ្ញាបត្រផ្នែករដ្ឋបាលពាណិជ្ជកម្មពីសាកលវិទ្យាជាតិគ្រប់គ្រងក្នុងឆ្នាំ ២០០២។ លោកបានប្រលងជាប់ និងក្លាយទៅជាសមាជិកACCAក្នុងឆ្នាំ២០០៩និងFCCA ក្នុងឆ្នាំ ២០១៤។ នៅក្នុងខែកញ្ញា ឆ្នាំ ២០១៩ លោកទទួលបាន “Certified Expert in Risk Management” ដោយសញ្ញាបត្រចេញពី Frankfurt School of Finance and Management ប្រទេសអាឡឺម៉ង់។

**លោក ហុង ឡុងឌី**

**នាយកប្រតិបត្តិសវនកម្មផ្ទៃក្នុង**

លោក ហុង ឡុងឌី មានបទពិសោធន៍ធ្វើការជាង១៧ឆ្នាំ នៅក្នុងវិស័យធនាគារ និងនៅក្រុមហ៊ុនគណនេយ្យធំមួយនៅប្រទេសកម្ពុជា។ មុនពេលចូលបម្រើការនៅ ធនាគារស្ថាបនា លោកគឺជាសវនករនៅ PricewaterhouseCoopers ក្នុងប្រទេសកម្ពុជាផ្នែក Assurance and Advisory។ លោកបានបម្រើសេវាដល់អតិថិជនជាច្រើន ជាពិសេសនៅឧស្សាហកម្មទូរគមនាគមន៍ និងធនាគារ។ នៅឆ្នាំ ២០១៣ លោក ឡុងឌី ចូលបម្រើការនៅម៉ារ៉ូហាន់ ធនាគារជប៉ុន ជាប្រធានសវនកម្មផ្ទៃក្នុងរហូតដល់ការរួមបញ្ចូល នៅឆ្នាំ២០១៦ ជាធនាគារ ស្ថាបនា។ តាំងពីឆ្នាំ២០១៦ លោកបានដឹកនាំកិច្ចការងារផ្សេងៗរួមមាន ការគ្រប់គ្រងហានិភ័យ និងការអនុលោមប្រតិបត្តិការ ហានិភ័យទីផ្សារ ព្រមទាំងសវនកម្មផ្ទៃក្នុង។ លោក ឡុងឌី ទទួលបានបរិញ្ញាបត្ររដ្ឋបាលពាណិជ្ជកម្ម ពីវិទ្យាស្ថានបច្ចេកវិទ្យា និងគ្រប់គ្រងវិញ្ញាបនបត្រ CAT និងACCA ពីសមាគមអ្នកជំនាញគណនេយ្យ និងវិញ្ញាបនបត្រអ្នកជំនាញផ្នែកគ្រប់គ្រងហានិភ័យពីសាលាFrankfurហិរញ្ញវត្ថុ និងគ្រប់គ្រង នៅប្រទេសអាល្លឺម៉ង់។ លោកក៏ជា FCCA ដែលជាសមាជិកនៃ IIAP និង KICPAA ផងដែរ។

**លោក ណក់ ពេជ្រកោសា**

**នាយកប្រតិបត្តិបច្ចេកវិទ្យាព័ត៌មាន**

លោក ណាក់ ពេជ្រកោសា មានបទពិសោធន៍បច្ចេកវិទ្យាជាង១៩ ឆ្នាំជាមួយក្រុមហ៊ុនអន្តរជាតិ និងវិទ្យាស្ថានហិរញ្ញវត្ថុ។ មុននឹងចូលបម្រើការនៅធនាគារ ស្ថាបនា គាត់ជាប្រធានផ្នែកព័ត៌មានវិទ្យានៅធនាគារ J Trust រ៉ូយ៉ាល់។ លោកបានធ្វើការនៅធនាគារ ANZ និងធនាគារ J Trust រ៉ូយ៉ាល់អស់រយៈពេល៨ឆ្នាំ។ លោក កោសា ទទួលបានអនុបណ្ឌិតផ្នែករដ្ឋបាលពាណិជ្ជកម្មពីសាលកវិទ្យាល័យន័រតុននិងបរិញ្ញាបត្រផ្នែកព័ត៌មានសេដ្ឋកិច្ចពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត។លោកក៏ទទួលបាននូវវិញ្ញាបនបត្រអន្តរជាតិនៅITIL COBIT CPISI អ្នកដឹកនាំការអនុវត្ត ISMS ISO 27001:2013និងតម្រូវការQMSISO9001:2015។

**លោក កុយ ចំរើនវិជ្ជា**

**នាយកប្រតិបត្តិ ប្រតិបត្តិការឥណទាន**

លោក កុយ ចំរើនវិជ្ជា មានបទពិសោធន៍បម្រើការងារក្នុងវិស័យធនាគាររយៈពេលជាង ១៥ឆ្នាំ ហើយមុនពេលចូលបម្រើការងារនៅធនាគារ ស្ថាបនា លោកបានបម្រើការងារនៅ ធនាគារ វឌ្ឍនៈ អស់រយៈពេលជាង ៨ឆ្នាំ។ លោកបានចូលបម្រើការងារជាមួយ ធនាគារ ស្ថាបនា ជាអនុប្រធាន នាយកដ្ឋានឥណទានក្នុងខែកញ្ញាឆ្នាំ២០១៥ក្រោយមកលោកត្រូវបានតែងតាំងជានាយកដ្ឋានប្រតិបត្តិការឥណទាននៅខែមេសា ឆ្នាំ ២០១៨ ដោយបានគ្រប់គ្រងផ្នែកជាច្រើន ដូចជាផ្នែកការវិភាគ និងវាយតម្លៃឥណទានខ្នាតតូច និងមធ្យម និងឥណទានពាណិជ្ជកម្ម ផ្នែករដ្ឋបាលឥណទាន និងផ្នែកវាយតម្លៃទ្រព្យបញ្ចាំ។ អស់ជាច្រើនឆ្នាំកន្លងមកនេះ លោកបានដឹកនាំផ្នែកឥណទាន និងសម្រេចបាននូវលទ្ធផលដ៏គាប់ប្រសើរជាច្រើនផងដែរ។ លោកបានដឹកនាំក្រុមការងារគ្រប់គ្រងគម្រោងបានដោយជោគជ័យក្នុងការបង្កើត និងកំណត់ស្តង់ដារ នៃផលិតផលឥណទាន និងមាត្រដ្ឋាននៅក្នុងប្រព័ន្ធធនាគារស្នូល និងអភិវឌ្ឍនីតិវិធីប្រតិបត្តិការស្តង់ដារ គោលនយោបាយកំណែទម្រង់ប្រតិបត្តិការ និងធ្វើឱ្យមានស្វ័យប្រវត្តិកម្ម។ លោកក៏បានដឹកនាំក្រុមការងារ រដ្ឋបាលឥណទានដើម្បីកែលម្អគុណភាពទិន្នន័យនៅក្នុងប្រព័ន្ធធនាគារស្នូល ដែលបានធ្វើឱ្យធនាគារ ស្ថាបនាបានទទួលពានរង្វាន់គុណភាពទិន្នន័យពីក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី (ស៊ីប៊ីស៊ី) ក្នុងខែតុលា ឆ្នាំ២០១៧ ។បច្ចុប្បន្ន លោកត្រូវបានតែងតាំងជានាយកប្រតិបត្តិ ប្រតិបត្តិការឥណទាននៃធនាគារ ស្ថាបនា ក្នុងខែឧសភាឆ្នាំ២០២២។ លោក វិជ្ជា បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្មជំនាញគ្រប់គ្រងនៅសាកលវិទ្យាល័យន័រតុនក្នុងប្រទេសកម្ពុជាក្នុង ឆ្នាំ២០១០ និងទទួលបានបរិញ្ញាបត្រផ្នែកគ្រប់គ្រងក្នុងឆ្នាំ២០០៧។

**អ្នកស្រី ឈឹម សំអុល**

**នាយិកាប្រតិបត្តិ ធនធានមនុស្ស និងនីតិកម្ម**

អ្នកស្រី ឈឹម សំអុល គឺជាសមាជិកដ៏សំខាន់មួយរូបនៃគណៈគ្រប់គ្រងជាន់ខ្ពស់ ធនាគារ ស្ថាបនាដែលនាពេលបច្ចុប្បន្ននេះ អ្នកស្រីមានតួនាទីជានាយិកាប្រតិបត្តិ ធនធានមនុស្ស និងនីតិកម្ម ដោយគ្រប់គ្រងនាយកដ្ឋានចំនួន ០២ រួមមាន៖ នាយកដ្ឋានធនធានមនុស្ស និងនាយកដ្ឋាននីតិកម្ម/លេខាធិការដ្ឋាន។ សូមបញ្ជាក់ផងដែរថា អ្នកស្រី សំអុល ក៏ជាមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ជាមួយនឹងបទពិសោធន៍ក្នុងរយៈពេលជាង ១០ឆ្នាំ ក្នុងការផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ប្រកប ដោយគុណភាព ក៏ដូចជាការទទួលបានទំនុកចិត្តខ្ពស់ពីសំណាក់អតិថិជនទាំងក្នុងស្រុក និងក្រៅស្រុក ដោយរួមមានទាំងការផ្តល់ប្រឹក្សាផ្នែកពាណិជ្ជកម្ម/រដ្ឋប្បវេណី និងព្រហ្មទណ្ឌ ដែលលើសពីនេះ អ្នកស្រី ក៏ជាមេធាវីមួយរូប

ដែលទទួលស្គាល់ពីនិយ័តករមូលបត្រកម្ពុជា ក្នុងការប្រឹក្សាយោបល់ផ្នែកច្បាប់ក្នុងវិស័យមូលបត្រកម្ពុជាផងដែរ។ចំពោះប្រវត្តិការសិក្សា អ្នកស្រី សំអុល គឺជាបេក្ខបណ្ឌិតដែលកំពុងសិក្សានៅរាជបណ្ឌិត្យសភាកម្ពុជា និងទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិភូមិបាលពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងសាកលវិទ្យាល័យ Lumière Lyon 3។អ្នកស្រីក៏ជាអតីតនិស្សិតដែលទទួលបាន"អាហារូបករណ៍រាជរដ្ឋាភិបាលកម្ពុជា"ក្នុងកំឡុងឆ្នាំ២០០៤-២០០៨ សម្រាប់បរិញ្ញាបត្រផ្នែកច្បាប់ពីសាកលវិទ្យា ល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាល័យ Lumière Lyon 2។ លើសពីនេះ អ្នកស្រី ក៏ទទួលបានបរិញ្ញាបត្រផ្នែកបង្រៀនភាសាអង់គ្លេសជាភាសាបរទេស (TEFL) ពីវិទ្យាស្ថានភាសាបរទេស (IFL) នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។បន្ថែមពីប្រវត្តិសិក្សាខាងលើ អ្នកស្រី សំអុល ទើបតែទទួលបានគុណវុឌ្ឍិពី CEDR Mediator នៃចក្រភពអង់គ្លេសនៅដើមឆ្នាំ២០២២ ហើយអ្នកស្រីក៏ជាសមាជិករបស់ SIArb (Singapore Institute of Arbitration) តាំងពីឆ្នាំ២០១៧ ក៏ដូចជាអតីតនិស្សិតស្រាវជ្រាវនៅសាកលវិទ្យាល័យ National University of Singapore ក្នុងឆ្នាំ២០១០[3]។

## ៣.២ នីតិវិធីនៃការផ្តល់ឥណទាន

ចំពោះនីតិវិធីក្នុងការផ្តល់ឥណទានរបស់ធនាគារស្ថាបនារួមមានប្រាំបួនដំណាក់កាលដូចជា៖

### ៣.២.១ ដំណាក់កាលទី១៖ ការដាក់ពាក្យសុំចុះឈ្មោះខ្ចីប្រាក់

- អ្នកដាក់ពាក្យសុំចុះឈ្មោះខ្ចីប្រាក់មកជួបភ្នាក់ងារបម្រើអតិថិជន នៅការិយាល័យរបស់ធនាគារស្ថាបនា
- ភ្នាក់ងារអតិថិជនធ្វើការពន្យល់ពីគោលការណ៍ នីតិវិធីឥណទាន តម្រូវការសម្រាប់ធនាគារស្ថាបនា និងលក្ខខណ្ឌរួម ក្នុងការខ្ចីឥណទានតម្រូវឱ្យបានច្បាស់លាស់ទៅអ្នកចុះឈ្មោះសុំខ្ចីប្រាក់។
- ភ្នាក់ងារបម្រើអតិថិជនផ្តល់ពាក្យសុំចុះឈ្មោះខ្ចីប្រាក់ ជូនទៅអតិថិជន និងជម្រាបអំពីតម្រូវការឯកសារសម្រាប់ធនាគារ។
- ប្រសិនពាក្យសុំចុះឈ្មោះមិនទាន់ពេញលេញច្បាស់លាស់ គ្រប់គ្រាន់ភ្នាក់ងារបម្រើអិតិថិជនត្រូវជួយបំពេញចំណុចខ្វះខាតទាំងអស់នោះ។
- ក្រោយពីទទួលពាក្យខ្ចីប្រាក់ដែលបានបំពេញត្រឹមត្រូវរបស់អតិថិជន និងពិនិត្យរួចរាល់ហើយភ្នាក់ងារបម្រើអតិថិជនត្រូវដាក់ពាក្យនោះ ក្នុងឯកសាររបស់ភ្នាក់ងារឥណទានទទួលខុសត្រូវ។
- អ្នកស្នើសុំខ្ចីប្រាក់អាចទាក់ទងដាក់ពាក្យជាមួយភ្នាក់ងារឥណទាន ក្នុងពេលដែលភ្នាក់ងារឥណទានធ្វើការនៅមូលដ្ឋាន។

### ៣.២.២ ដំណាក់កាលទី២៖ ការសិក្សាពីលទ្ធភាពរបស់អតិថិជន

ការសិក្សាពីលទ្ធភាពរបស់អតិថិជនចែកចេញជាបីដំណាក់កាលគឺ៖

ក. ការចុះសិក្សាដល់លំនៅដ្ឋាន និងទីកន្លែងប្រកបអាជីវកម្មរបស់អតិថិជន

[3] https://www.sathapana.com.kh/kh/about-us 09/03/2024

- ក្រោយពីទទួលពាក្យសុំចុះឈ្មោះខ្ចីប្រាក់ភ្នាក់ងារឥណទានត្រូវចុះទៅជួបអតិថិជនដល់ផ្ទះ គឺដើម្បីសាកសួរព័ត៌មានអំពីតម្រូវការខ្ចីប្រាក់ និងលក្ខខណ្ឌផ្សេងៗទៀតផងដែរ។
- ភ្នាក់ងារឥណទានត្រូវយកចិត្តទុកដាក់ផ្តោតអារម្មណ៍ សាកសួរប្រមូលព័ត៌មានពីអ្នកខ្ចីប្រាក់ដែលទាក់ទងនិងព័ត៌មានទូទៅ ព័ត៌មានហិរញ្ញវត្ថុ គោលបំណងប្រើប្រាស់កម្ចីព័ត៌មានអំពីទ្រព្យសម្បត្តិដែលត្រូវបង្កើតហ៊ីប៉ូតែក សាកសួរអំពីកត្តាទាំងឡាយដែលជះឥទ្ធិពលបង្កឱ្យមានហានិភ័យ និងពន្យល់អតិថិជនឱ្យបានច្បាស់លាស់ពីគោលការណ៍ និងនីតិវិធីផ្តល់ឥណទានដោយរាប់បញ្ចូលកិច្ចសន្យាព្រមព្រៀងនានា។ល។
- ក្រោយពីបានធ្វើការវាយតម្លៃលទ្ធភាពរបស់អ្នកខ្ចីប្រាក់រួចមក ភ្នាក់ងារឥណទានត្រូវបញ្ជាក់ជូនអតិថិជន អំពីលទ្ធភាពដែលអាចទទួលយកបានលក្ខខណ្ឌឥណទាន និងបណ្តុះវិន័យដោយមិនត្រូវផ្តល់ទំហំឥណទានណាមួយឡើយ។
- ភ្នាក់ងារទទួលបន្ទុកត្រូវពន្យល់អិតិថិជន អំពីការប្រកាសរបស់ធនាគារជាតិនៃកម្ពុជាស្តីពីការបង្កើតប្រព័ន្ធចែករំលែកឥណទានដែលតម្រូវឱ្យគ្រប់ស្ថាប័ន ចូលទៅយកព័ត៌មានឥណទាន "កម្ពុជា" ដែលជាបន្ទុករបស់អតិថិជននិងត្រូវកាត់ចេញពីគណនី ឬបង់ជាសាច់ប្រាក់ផ្ទាល់នៅពេលអតិថិជនទទួលឥណទាន។
- ភ្នាក់ងារទទួលបន្ទុកពន្យល់អតិថិជនឱ្យបានច្បាស់លាស់ អំពីរាល់ការប្រកាសដែលបានចែងក្នុងទម្រង់គម្រូពាក្យស្នើសុំឥណទានជាពិសេស ព្រមទាំងការយល់ព្រមរបស់អតិថិជនក្នុងការអនុញ្ញាតឱ្យធនាគារ ផ្តល់ព័ត៌មានឥណទានរបស់ខ្លួនទៅការិយាល័យឥណទាន "កម្ពុជា" ទៅតាមតម្រូវការរបស់ច្បាប់ដែលមានចែងមក។

**ខ. ការសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមនៃអាជីវកម្មរបស់អតិថិជន**

- ភ្នាក់ងារឥណទានត្រូវចុះទៅដល់លំនៅដ្ឋានទីកន្លែងប្រកបអាជីវកម្មរបស់អតិថិជនផ្ទាល់ដើម្បីធ្វើការសិក្សាវាយតម្លៃលើកត្តាទាំងឡាយដែលពាក់ព័ន្ធទៅនិងបរិស្ថាន និងសង្គម។
- ក្នុងករណីរកឃើញថា អាជីវកម្មនោះមិនឆ្លើយតបទៅនឹងបទដ្ឋានណាមួយនៃបរិស្ថាននិងសង្គម ភ្នាក់ងារឥណទាន ត្រូវធ្វើការពន្យល់ដល់ម្ចាស់អាជីវកម្មឱ្យធ្វើការកែលម្អនូវរាល់ហេតុការទាំងឡាយ ដែលប៉ះពាល់បរិស្ថាន និងសង្គមដោយផ្អែកទៅលើអនុសាសន៍ និងរយៈពេលនៃផែនការសកម្មភាពអាជីវកម្មនោះ និងរបាយការណ៍ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមនៃអាជីវកម្មឱ្យមានភាពសមស្របឡើងវិញ។
- រាល់ការសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមនៃអាជីវកម្មរបស់អតិថិជនត្រូវផ្អែកទៅលើគោលការណ៍ប្រតិបត្តិបរិស្ថាន និងសង្គម និងនីតិវិធីវាយតម្លៃបរិស្ថាននិងសង្គម។

**គ. ការផ្ទៀងផ្ទាត់ជាមួយព័ត៌មានឥណទាននៃការិយាល័យឥណទាន"កម្ពុជា"**

- រាល់ព័ត៌មានដែលទទួលបានក្នុងកំឡុងពេលដែលចុះទៅសិក្សាដល់លំនៅស្ថាន និងកន្លែងប្រកបអាជីវកម្មរបស់អតិថិជនត្រូវតែផ្ទៀងផ្ទាត់បន្ថែម ជាមួយរបាយការណ៍ឥណទានដែល

បានផ្តល់ឱ្យដោយការិយាល័យឥណទាន "កម្ពុជា" ដើម្បីធ្វើការប្រាកដអំពីភាពជឿជាក់បានរបស់អតិថិជនមុននិងធ្វើការសម្រេចចិត្តផ្តល់ឬមិនផ្តល់ឥណទាន។

- ព័ត៌មានដែលប្រមូលបានមកពីការចុះសិក្សាដល់កន្លែងរបស់អតិថិជន គឺជាព័ត៌មានមូលដ្ឋានសម្រាប់ធ្វើការវិនិច្ឆ័យផ្តល់ឥណទាន។ ព័ត៌មានមួយចំនួនរបស់អតិថិជនត្រូវវាយបញ្ចូនទៅក្នុងប្រព័ន្ធព័ត៌មានចែករំលែកឥណទាននៃការិយាល័យឥណទាន "កម្ពុជា" ដើម្បីទាញរបាយការណ៍ឥណទានសម្រាប់ធ្វើការផ្ទៀងផ្ទាត់បន្ថែមទៀត មុននិងធ្វើការសម្រេចចិត្តផ្តល់ឥណទាន។
- ព័ត៌មាន ឬរបាយការណ៍ឥណទានដែលទទួលបានពីការិយាល័យឥណទាន "កម្ពុជា" ត្រូវបាត់ចែងប្រគល់ឱ្យភ្នាក់ងារ និងថ្នាក់ដឹកនាំមានសមត្ថកិច្ចដែលពាក់ព័ន្ធដើម្បីយកទៅសិក្សាវិភាគអំពីហានិភ័យ និងភាពដែលអាចជឿជាក់បានរបស់អតិថិជន មុននិងធ្វើការសម្រេចចិត្តផ្តល់ ឬមិនផ្តល់ឥណទាន។
- ការសម្រេចចិត្តក្នុងការផ្តល់ឥណទាន ឬមិនផ្តល់ឥណទានផ្អែកលើការពិនិត្យរបស់ថ្នាក់មានសមត្ថកិច្ចរបាយការណ៍ឥណទានដែលទទួលបានពីការិយាល័យឥណទាន "កម្ពុជា" គ្រាន់តែជាព័ត៌មានបន្ថែមសម្រាប់ជួយដល់ការវិនិច្ឆ័យឱ្យបានត្រឹមត្រូវតែប៉ុណ្ណោះ។

**៣.២.៣ ដំណាក់កាលទី៣៖ ការរៀបចំឯកសារខ្ចីប្រាក់**

- បន្ទាប់ពីអតិថិជនមានការព្រមព្រៀងគ្នាហើយ ភ្នាក់ងារឥណទានរៀបចំឯកសារសម្រាប់អតិថិជនខ្ចីប្រាក់ ក្នុងនោះមានសម្ភាសន៍ កំណត់ហេតុវាយតម្លៃទ្រព្យគម្រោងជំនួញ និងឱ្យអតិថិជនដាក់ពាក្យសុំខ្ចីប្រាក់។ គួរកត់សម្គាល់ថា ភ្នាក់ងារឥណទានអាចសរសេរយោបល់ និងសំណើរបស់ខ្លួន ដើម្បីសុំការអនុម័តបានលុះត្រាតែបានបង្កើតហ៊ីប៉ុតែក នៅក្នុងគម្រោងជំនួញ។
- ភ្នាក់ងារឥណទានត្រូវសរសេរយោបល់ និងសំណើរដោយបញ្ជាក់ពីទំហំឥណទានរយៈពេលខ្ចីនិងអត្រាការប្រាក់ ដើម្បីសុំធ្វើការអនុម័ត។

**៣.២.៤ ដំណាក់កាលទី៤៖ ការអនុម័តឥណទាន**

- ភ្នាក់ងារឥណទានត្រូវបញ្ចូនឯកសារខ្ចីប្រាក់ ដែលបានរៀបចំរួចហើយនោះដាក់ជូនមកអ្នកគ្រប់គ្រងដែលមានសិទ្ធិអនុម័តឥណទាន ដើម្បីសុំការអនុម័តឥណទានដែលបានផ្តល់ដោយនាយកប្រតិបត្តិឥណទានត្រូវមានយោបល់និងសំណើពីភ្នាក់ងារឥណទានទទួលខុសត្រូវមានការបញ្ជាក់ពីប្រធានការិយាល័យស្រុក ខណ្ឌ ឬប្រធានភ្នាក់ងារឥណទានពីនាយក លើពាក្យស្នើសុំឥណទានរួមជាមួយគម្រោងជំនួញ និងឯកសារសម្គាល់របស់អតិថិជនខ្លះទៀតផ្ញើមកនាយកដ្ឋានឥណទាន។
- ឥណទានដែលបានអនុម័តដោយគណៈកម្មាធិការឥណទាន ភ្នាក់ងារឥណទានត្រូវរៀបចំទម្រង់សំណើស្នើសុំឥណទានផ្នែកទីមួយ (Credit Proposal) ភ្ជាប់ជាមួយរបាយការណ៍ហិរញ្ញវត្ថុដែលដកចេញពីគម្រោងជំនួញ និងឯកសារសម្គាល់របស់អតិថិជន។ ភ្នាក់ងារឥណទានត្រូវធ្វើការសន្និដ្ឋាន និងសរសេរអនុសាសន៍ព្រមទាំងមានសេចក្តីបញ្ជាក់ពីប្រធានការិយាល័យស្រុក

ខណ្ឌ ឬប្រធានភ្នាក់ងារឥណទានពីនាយកធនាគាររួចហើយផ្ញើរមកនាយកដ្ឋានឥណទាន។ ផ្នែកវិភាគឥណទានហើយវិភាគសរសេរលើទម្រង់ផ្នែកទី២របស់ទម្រង់សំណើសុំឥណទាន រួចដាក់ជូននាយកប្រតិបត្តិដើម្បីពិនិត្យនិងបញ្ជូនទៅគណៈកម្មាធិការឥណទានប្រជុំពិភាក្សាអនុម័ត។

- ឥណទានដែលអនុម័តដោយគណៈកម្មាធិការឥណទាន និងហានិភ័យនៃក្រុមប្រឹក្សាភិបាល (CRC) ធនាគារស្ថាបនា ត្រូវបានឆ្លងតាមរយៈការប្រជុំ និងអនុសាសន៍របស់គណៈកម្មាធិការឥណទាន។

- **ការទទួលខុសត្រូវ និងសិទ្ធិអនុម័តឥណទាន**
  - ➢ ប្រធានភ្នាក់ងារឥណទានសាខា "ក" (លំដាប់សាខា)
  - ➢ នាយក-នាយិកាសាខា "ខ" (លំដាប់សាខា)
  - ➢ នាយក-នាយិកាសាខា "ក" (លំដាប់សាខា)
  - ➢ គណៈកម្មាធិការឥណទាន និងហិរញ្ញប្បទានពាណិជ្ជកម្ម
  - ➢ នាយកប្រតិបត្តិឥណទាន
  - ➢ គណៈកម្មាធិការឥណទាន
  - ➢ គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល។

**៣.២.៥ ដំណាក់កាលទី៥៖ ការរៀបចំកិច្ចសន្យា**

- បន្ទាប់ពីឥណទានអនុម័ត(យល់ព្រម) រួចហើយ ភ្នាក់ងារឥណទានត្រូវជួបអ្នកដាក់ពាក្យដល់ផ្ទះម្តងទៀតដើម្បីរៀបចំកិច្ចសន្យាក្នុងនោះមានកិច្ចសន្យាខ្ចីប្រាក់ កិច្ចសន្យាបង្កើតហ៊ីប៉ូតែក និងលិខិតផ្សេងៗដែលទាក់ទង។
- ភ្នាក់ងារឥណទានត្រូវទទួលខុសត្រូវលើការរៀបចំឯកសារទាំងអស់។
- បន្ទាប់ពីមានការយល់ព្រមព្រៀងហើយ អតិថិជននិងអ្នកដែលពាក់ព័ន្ធទាំងអស់ត្រូវផ្តិតមេដៃ ឬចុះហត្ថលេខានៅចំពោះមុខភ្នាក់ងារឥណទាន។ ចំពោះឯកសារណា ដែលត្រូវបញ្ជាក់ពីអាជ្ញាធរអតិថិជនត្រូវរត់ការសុំបញ្ជាក់ចុះហត្ថលេខា បោះត្រានិងចុះកាវីបន្ទុកលើវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ(ប្លង់រឹង) ពីការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុកខណ្ឌ ឬការិយាល័យទទួលបន្ទុកពីមន្ទីររៀបចំដែន នគរូបនីយកម្មសំណង់ និងសុរិយោដីខេត្ត រាជធានី។ ឯកសារមួយចំនួនទៀតត្រូវប្រគល់ជូនទៅភ្នាក់ងារឥណទានដែលត្រូវប្រគល់ទៅភ្នាក់ងារបម្រើអតិថិជនបន្ត។
- ក្រោយពីឯកសារទាំងនោះបានបំពេញត្រឹមត្រូវ គ្រប់គ្រាន់ និងបានចុះហត្ថលេខាបញ្ចប់សព្វគ្រប់ហើយ អតិថិជនត្រូវកាន់ឯកសារទាំងនោះទៅឱ្យភ្នាក់ងារបម្រើអតិថិជន។
- ចំពោះដី អគារដែលឯកសារកម្មសិទ្ធិពុំមានប្លង់រឹង ត្រូវសម្រេចដោយនាយកប្រតិបត្តិឥណទាន។

**៣.២.៦ ដំណាក់កាលទី៦៖ ការរៀបចំបញ្ចូលទន្លន័យ**

- ភ្នាក់ងារបម្រើអតិថិជន ក្រោយពីទទួលឯកសារហើយ ត្រូវត្រួតពិនិត្យឯកសារទាំងនោះឱ្យបានត្រឹមត្រូវ៖

- ពិនិត្យមើលការចុះហត្ថលេខារបស់ឃុំ សង្កាត់ ស្រុក ខណ្ឌ សុរិយោដីនៅលើឯកសារឱ្យបានត្រឹមត្រូវ
- ក្នុងករណីបញ្ចេញឥណទានក្នុងប្រព័ន្ធ Globus ត្រូវបង្កើត GIF និងបើកគណនី( ពាក្យសុំចុះឈ្មោះបើកគណនី ពាក្យបើកគណនី គំរូហត្ថលេខា )។
- រួចបញ្ជូនឯកសារទាំងនោះទៅឱ្យគណនេយ្យករ។
- បន្ទាប់ពីបញ្ជូនឯកសារទាំងនោះឱ្យគណនេយ្យកររួចហើយ ភ្នាក់ងារបម្រើអតិថិជនរងចាំទទួលប្រាក់កម្ចី
- គណនេយ្យករដែលពាក់ព័ន្ធត្រូវត្រួតពិនិត្យលើឯកសារទាំងនោះរួមមាន៖
- ឯកសារទាំងនោះត្រូវតែមានភាពត្រឹមត្រូវ ច្បាស់លាស់ គ្រប់គ្រាន់។
- ក្នុងករណីបញ្ចេញឥណទានក្នុងប្រព័ន្ធ Globus គណនេយ្យករត្រូវបានបញ្ជូនទិន្នន័យទៅក្នុងប្រព័ន្ធរួចប្រធានគណនេយ្យករត្រូវ Authorize។
- បោះពុម្ពតារាងកាលវិភាគសងប្រាក់ សរសេរបង្កាន់ដៃតម្កល់ទ្រព្យធានា និងប័ណ្ណចំណាយឱ្យខ្ចី ឬរៀបចំឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធ។
- បញ្ជូនសំណុំឯកសាររបស់អតិថិជនទៅថ្នាក់ដឹកនាំមានសមត្ថកិច្ច ដើម្បីចុះហត្ថលេខា។

**៣.២.៧ ដំណាក់កាលទី៧៖ ការបញ្ចេញឥណទាន**

- គ្រប់ឯកសារទាំងអស់ដែលទាក់ទង និងការបញ្ចេញឥណទានត្រូវរៀបចំឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវមុនពេលបញ្ចេញ ហើយបញ្ជូនទៅឱ្យបេឡាធិការរៀបចំប្រាក់រង់ចាំអតិថិជនមកបើក។
- ពេលអតិថិជនឱ្យទៅជួបបេឡាធិការ ដើម្បីបើកប្រាក់ ឬផ្ទេរប្រាក់ចូលគណនីរបស់អតិថិជន។ មុនពេលបើកប្រាក់ បេឡាធិការត្រូវរំលឹកឡើកវិញពីលក្ខខណ្ឌមួយចំនួនដូចជា ការសងប្រាក់ ការពិន័យលើការប្រាក់យឺតយ៉ាវ និងការប្រគល់ ទទួលប្រាក់ត្រូវតែពិនិត្យ និងរាប់ប្រាក់ឱ្យបានត្រឹមត្រូវ មុនពេលចាកចេញពីបញ្ជា។
- បេឡាធិការឱ្យអតិថិជនផ្តិតមេដៃលើប័ណ្ណប្រាក់ឱ្យខ្ចី ឬប័ណ្ណដកប្រាក់ ហើយប្រគល់ប្រាក់ជូនអតិថិជន។

**៣.២.៨ ដំណាក់កាលទី៨៖ ការតាមដានប្រាក់សំណង និងការប្រមូលប្រាក់សំណង**

- ភ្នាក់ងារឥណទានត្រូវការតាមដានការសងប្រាក់មកវិញរបស់អតិថិជនតាមរយៈរបាការណ៍ Repayment in Arrears ដែលនិងត្រូវបោះពុម្ពជាប្រចាំថ្ងៃ។
- នៅពេលដែលរបាយការណ៍បានបង្ហាញពីភាពយឺតយ៉ាវនៃការសងប្រាក់ចាប់ពី ១ថ្ងៃឡើងទៅ ភ្នាក់ងារឥណទានត្រូវចុះជួបអតិថិជនជាបន្ទាន់ដល់លំនៅដ្ឋាន ឬនៅទីតាំងអាជីវកម្ម និងជំរុញឱ្យអតិថិជនមកបង់ប្រាក់ដល់ការិយាល័យរបស់ ធនាគារស្ថាបនា ភីអិលស៊ី។
- ទឹកប្រាក់សំណងទាំងអស់ដែលប្រមូលបានពីអតិថិជនត្រូវប្រគល់ឱ្យបេឡាធិការផ្នែកប្រតិបត្តិការសាខា និងធ្វើការកាត់សងឥណទាននៅក្នុងមួយថ្ងៃដដែល។

- ក្នុងករណីដែលភ្នាក់ងារដោះស្រាយបំណុលទទួលបានប្រាក់សំណងពីអតិថិជនក្រោយម៉ោងធ្វើការ ត្រូវជូនដំណឹងទៅថ្នាក់គ្រប់គ្រងឱ្យបានជ្រាបព័ត៌មាន និងត្រូវធ្វើការប្រគល់ជូនបេឡាធិការ/ភ្នាក់ងារ ប្រតិបត្តិការសាខា នៅថ្ងៃធ្វើការបន្ទាប់។

**៣.២.៩ ដំណាក់កាលទី៩៖ ការចុះដោះស្រាយបញ្ហាខានសងប្រាក់**

- ភ្នាក់ងារឥណទានត្រូវប្រកាន់ខ្ជាប់នូវសីលធម៌ កាយ វាចា ចិត្ត ក្នុងការដោះស្រាយបញ្ហាខកខានសងប្រាក់ ដោយមិនគំរាមគំហែង មិនប្រទើ្បលបើស មិនអសីលធម៌។
- ជ្រើសរើសពេលវេលា និងទីកន្លែងសមស្របក្នុងការដោះស្រាយបញ្ហា និងយកកិច្ចសន្យាខ្ចីប្រាក់ដែលអតិថិជនបានផ្តិតមេដៃជាមួយធនាគារធ្វើជាមូលដ្ឋាន ក្នុងការដោះស្រាយ។
- រាល់ការដោះស្រាយបញ្ហាឥណទានត្រូវអនុលោមតាមគោលការណ៍ណែនាំស្តីពីដំណោះស្រាយឥណទានខកខានសង។

❖ **ការស្នើសុំខ្ចីប្រាក់បន្ត៖**

- នៅពេលអតិថិជនសងបំណុលចប់ អតិថិជនស្នើសុំខ្ចីប្រាក់បន្ត ភ្នាក់ងារបម្រើអតិថិជនត្រូវផ្តល់ពាក្យសុំចុះឈ្មោះខ្ចីប្រាក់ជូនអតិថិជនដើម្បីបំពេញ។ ពេលអតិថិជនបំពេញពាក្យសុំចុះឈ្មោះខ្ចីប្រាក់និងផ្តិតមេដៃស្តាំរួច ភ្នាក់ងារបម្រើអតិថិជនត្រូវកត់ត្រាលេខសម្គាល់អតិថិជន ឬលេខកិច្ចសន្យាខ្ចីប្រាក់ លើពាក្យស្នើសុំនោះរួចបញ្ជូនទៅឱ្យគណនេយ្យករ។
- គណនេយ្យករត្រូវបោះពុម្ពតាមដានលម្អិតនៃការសងប្រាក់របស់អតិថិជនរួចភ្ជាប់ជាមួយពាក្យសុំចុះឈ្មោះខ្ចីប្រាក់បញ្ជូនទៅឱ្យភ្នាក់ងារបម្រើអតិថិជន ឬជំនួយការរដ្ឋាភិបាល ដើម្បីប្រគល់ឱ្យភ្នាក់ងារឥណទានសម្រាប់ចុះជួបអតិថិជន

## ៣.៣ កត្តាដែលបណ្តាលឱ្យកើតមានហានិភ័យឥណទាន

### ៣.៣.១ កត្តាដែលបណ្តាលមកពីអតិថិជន

- រំលោភកិច្ចព្រមព្រៀងដែលមានចែងក្នុងកិច្ចសន្យា
- បាត់បង់ប្រាក់ចំណូលប្តូរមុខរបរមិនទៀងទាត់
- មានទំនាស់ក្នុងក្រុមគ្រួសារ
- ធ្វើការងារដោយគ្មានគម្រោង
- ផ្លាស់ប្តូរទីកន្លែងរស់នៅ រកស៊ីឆ្ងាយពីតំបន់ដែលខ្លួនទទួលឥណទាន
- ជួបបញ្ហាក្នុងដំណើរការមុខរបរ ជំនួញបរាជ័យ
- អតិថិជនមើលបំណាំគ្នាក្នុងភូមិតែមួយឬសមាជិកក្រុម
- អតិថិជនបន្លំទ្រព្យធានា
- ឥណទានមួយចំនួន ជាឥណទានបន្តដៃគ្នា ឈរឈ្មោះខ្ចីឱ្យគេ....។

### ៣.៣.២ កត្តាដែលបណ្តាលមកពីធនាគារ

- អនុវត្តប្រាស់ចាកពីគោលនយោបាយ នីតិវិធី និងសេចក្តីណែនាំអំពីការផ្តល់ឥណទាន
- ធ្វើការគ្មានផែនការច្បាស់លាស់ ដោយមិនគោរពទៅតាមការណាត់ជួបជាមួយអតិថិជន
- សិក្សាតាមតំបន់ និងរដូវកាលនៃការប្រតិបត្តិការមិនច្បាស់លាស់

- មិនបានសិក្សាឱ្យស៊ីជម្រៅ អំពីអត្តចរិករបស់អតិថិជន
- វាយតម្លៃទ្រព្យធានាមិនបានត្រឹមត្រូវ
- សិក្សាមិនបានស៊ីជម្រៅលើលំហូរសាច់ប្រាក់របស់អតិថិជន
- សិក្សាមិនបានស៊ីជម្រៅ ពីសក្តានុពលមុខរបរលើទីផ្សាររបស់អតិថិជន
- ធ្វេសប្រហែសក្នុងការបំពេញឯកសារ
- ឃុបឃិតជាមួយអតិថិជនកេងបន្លំឥណទាន។

**៣.៣.៣ កត្តាដែលបណ្តាលមកពីប្រធានសក្តិ**

- គ្រោះធម្មជាតិ៖ ជួបនូវគ្រោះមហន្តរាយខ្យល់ព្យុះ គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត គ្រោះរញ្ជួយផែនដីឬផ្ទុះភ្នំភ្លើង
- សង្គម៖ ការផ្ទុះឡើងនៃសង្គ្រាម ការប្រែប្រួលសេដ្ឋកិច្ច ការផ្លាស់ប្តូររដ្ឋាភិបាល ឬគោលនយោបាយនានា
- សេដ្ឋកិច្ច៖ ការផ្ទុះឡើងនូវវិបត្តិសេដ្ឋកិច្ចពិភពលោក និងវិបត្តិហិរញ្ញវត្ថុជាដើម។

## ៣.៤ មធ្យោបាយក្នុងការគ្រប់គ្រងហានិភ័យឥណទានឱ្យមានប្រសិទ្ធភាព

### ៣.៤.១ មធ្យោបាយគ្រប់គ្រងហានិភ័យ និងការទប់ស្កាត់ចំពោះអតិថិជន

- ស្វែងយល់ពីគោលបំណងនៃការខ្ចីប្រាក់
- វិភាគនូវរបាយការណ៍ហិរញ្ញវត្ថុឱ្យបានហ្មត់ចត់
- ពិចារណាលើគោលជំហររបស់អ្នកខ្ចីប្រាក់( ប្រវត្តិរូប ប្រវត្តិអាជីវកម្មជាដើម )
- អតិថិជនត្រូវតែមានវត្ថុបញ្ចាំ ឬអ្នកធានា
- ពិនិត្យមើលអត្តចរិក ឬចរិកលក្ខណៈអាកប្បកិរិយារបស់អ្នកខ្ចីបប្រាក់
- អិតិជនត្រូវតែជាម្ចាស់កម្មសិទ្ធិនៃទ្រព្យដាក់បញ្ចាំ.......។

### ៣.៤.២ មធ្យោបាយគ្រប់គ្រងហានិភ័យ និងការទប់ស្កាត់ចំពោះធនាគារ

- ជ្រើសរើសបុគ្គលិកដែលមានចំណេះដឹង ជំនាញ បទពិសោធន៍ ឆន្ទៈ ចំពោះការងារ
- ធ្វើការបណ្តុះបណ្តាលបន្ថែម ចំពោះបុគ្គលិកដែលមិនមានសមត្ថភាព
- បណ្តុះគំនិតបុគ្គលិកឱ្យមានភាពស្មោះត្រង់ចំពោះធនាគារជានិច្ច
- ធ្វើការផាកពិន័យឬដាក់ទោសចំពោះបុគ្គលិកដែលមានកំហុសដោយចេតនា
- ធ្វើការលើកទឹកចិត្តទៅលើបុគ្គលិកណា ដែលបានបំពេញការងារបានល្អ
- ណែនាំបុគ្គលិកឱ្យឯកភាពក្នុងការបំពេញការងារនិងមានទំនួលខុសត្រូវលើការងារ។

# ជំពូកទី៤

# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ក្រោយពីបានសិក្សាស្រាវជ្រាវទៅលើប្រធានបទរួចមក ក្រុមយើងខ្ញុំឃើញថា ការគ្រប់គ្រងហានិភ័យឥណទានក្នុងការផ្តល់ឥណទានរបស់ធនាគារស្ថាបនា ភីអិលស៊ី មានសារៈសំខាន់ខ្លាំងណាស់ដល់ធនាគារ និងអ្នកប្រើប្រាស់។ តែទោះជាយ៉ាងណាក៏ដោយនៅតែមានចំណុចខ្លាំង និងចំណុចខ្សោយ ទៅជាមួយគ្នាហើយខាងក្រោមនេះជាចំណុចខ្លាំង និងចំណុចខ្សោយ ដែលទាក់ទងនិងប្រធានបទ។

## ៤.១ ការវិភាគលើចំណុចខ្លាំង

**ភាពខ្លាំងរបស់ធនាគារស្ថាបនាមានដូចជា៖**

- ផ្តល់ឥណទានសម្រាប់អតិថិជនបានយ៉ាងឆាប់រហ័ស និងទទួលបានព័ត៌មានកាន់តែច្បាស់ជាងមុនក្នុងការសម្រេចចិត្តផ្តល់ឥណទានឱ្យបានត្រឹមត្រូវជាងមុន។ ហើយជួយដល់ថ្នាក់គ្រប់គ្រងឥណទានវាយតម្លៃទៅលើគុណភាពឥណទានរបស់អតិថិជន បានឆាប់រហ័សជាងមុន និងធ្វើការសម្រេចចិត្តកាន់តែមានភាពសុក្រិត។
- ធនាគារ មានគោលការណ៍ត្រួតពិនិត្យយ៉ាងម៉ត់ចត់មុន និងក្រោយពេលផ្តល់ឥណទានដោយចាត់ ឱ្យភ្នាក់ងាររៀបចំឯកសារធ្វើការចុះស៊ើបអង្កេតដល់ផ្ទះ វាយតម្លៃទៅលើមុខរបរ ទ្រព្យបញ្ចាំ ទំហំឥណទាន និង ការសម្រេចចិត្តថាត្រឹមត្រូវទៅតាមគោលការណ៍ និងនីតិវិធីរបស់ធនាគារដែលបានកំណត់ ហើយភ្នាក់ងារអាចធ្វើការអនុម័តទៅលើទឹកប្រាក់ដែលអតិថិជនសុំស្នើខ្ចីនោះ ភ្នាក់ងារត្រូវសហការជាមួយនឹងប្រធាន ដើម្បីវាយតម្លៃទៅលើឥណទាននោះ។
- ធនាគារ មានការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងប្រព័ន្ធផ្ទៃក្នុង និងការគ្រប់គ្រងបុគ្គលិកមានភាពច្បាស់លាស់។

ជាមួយគ្នានេះ ដែលភ្នាក់ងារ និងបុគ្គលិកទាំងអស់មានទំនាក់ទំនងល្អ ជាមួយអតិថិជន អាជ្ញាធរមូលដ្ឋាន និងស្ថាប័នផ្សេងៗ ដែលជាហេតុធ្វើឱ្យមានដំណើរការ ការងារមានភាពរលូន។ ទន្ទឹមនិងនោះដែលការបែងចែកតួនាទីទៅតាម ឋានានុក្រម របស់បុគ្គលិកគ្រប់ផ្នែកទាំងអស់ ថែមទាំងមានការជុំរុញលើកទឹកចិត្តពីថ្នាក់ដឹកនាំបង្កឱ្យបរិយាកាសការងារ នៅក្នុងធនាគារ មានភាពល្អប្រសើរ។ លើសពីនេះទៅទៀត ការពិនិត្យជាប្រចាំថ្ងៃក្រោយពីបញ្ចេញឥណទានបាន ធ្វើឱ្យប្រសិទ្ធភាពនៃការបញ្ចេញឥណទាន និងប្រមូលឥណទានមានកម្រិតខ្ពស់ និងអាចទប់ស្កាត់ព្រមទាំងរកដំណោះស្រាយបានទាន់ពេលវេលា ចំពោះឥណទានដែលមានបញ្ហា។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ទោះបីជាធនាគារស្ថាបនា មានចំណុចខ្លាំងដូចដែលបានរៀបរាប់ខាងលើយ៉ាងណាក៏ដោយ ក៏ធនាគារនៅមានចំណុចខ្វះខាតមួយចំនួនដែលជាឧបសគ្គក្នុងការគ្រប់គ្រងហានិភ័យឥណទានផងដែរ។

**ចំណុចខ្វះខាតទាំងនោះមានដូចខាងក្រោម៖**

- សេដ្ឋកិច្ចធ្លាក់ចុះធ្វើឱ្យប៉ះពាល់ដល់ការរកចំណូលរបស់អតិថិជន ដូច្នេះពួកគាត់លែងមានលទ្ធភាពបង់សងទៅធនាគារប្រចាំខែដូចមុនទៀត។

- ទៅលើការផ្សព្វផ្សាយសេវារបស់ធនាគារ ហាក់បីដូចជានៅមានកម្រិត ជាក់ស្តែងបើនិយាយពីឥណទានរបស់ធនាគារមិនសូវមានប្រជាជនដឹងច្រើននៅឡើយទេ។
- ផ្តល់កម្ចីដោយមិនបានសិក្សាពីគោលបំណងរបស់អតិថិជនឱ្យបានច្បាស់លាស់ថា អតិថិជន គាត់យកកម្ចីទៅធ្វើអ្វី ឬបំពេញតម្រូវការត្រឹមត្រូវដែរឬទេ។ ឧទាហរណ៍៖ ទៅប្រកបអាជីវកម្ម ឬក៏យកទៅប្រើប្រាស់ផ្តេសផ្តាស...។

ដូចដែលបាននិយាយទាំងអស់ខាងលើនេះ សុទ្ធតែជាចំណុចខ្លាំង និងចំណុចខ្សោយ មួយចំនួនដែលក្រុមរបស់យើងខ្ញុំ បានយល់បន្ទាប់ពីបានសិក្សា និងស្រាវជ្រាវអំពីធនាគារស្ថាបនា បើចំណុចណាមួយដែលមិនសមស្របក្រុមរបស់យើងខ្ញុំ ក៏សូមខន្តីអភ័យទោសពីសំណាក់ លោកគ្រូ អ្នកគ្រូក៏ដូចជាសាស្ត្រាចារ្យនិងធនាគារស្ថាបនាផងដែរ ព្រោះនេះគ្រាន់តែជាការស្រាវជ្រាវ និងការយល់ឃើញពីក្រុមរបស់យើងខ្ញុំតែប៉ុណ្ណោះ ដោយក្រុមរបស់ខ្ញុំមិនមានបំណងអ្វីផ្សេងនោះទេ ហើយក្រុមរបស់យើងខ្ញុំក៏រីករាយនិងកែរាល់កំហុសដែលបានផ្តល់ជូនដល់ក្រុមរបស់យើងខ្ញុំ។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

បន្ទាប់ពីក្រុមយើងខ្ញុំបានសិក្សាស្រាវជ្រាវ និងប្រមូលឯកសារមួយរយៈកន្លងមកលើប្រធានបទ ស្តីពី ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារស្ថាបនា ភីអិលស៊ី ក្រុមយើងខ្ញុំអាចវិភាគ និងសន្និដ្ឋានបានថា ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារស្ថាបនា ពិតជាមានដំណើរការល្អប្រសើរពិតប្រាកដមែន ដោយធនាគារបានរៀបចំនីតិច្បាស់លាស់មុននឹងផ្តល់ឥណទានជូនអតិថិជនដែលរួមមានដូចជា ការសិក្សាអំពីចរិកលក្ខណៈដើមទុន សមត្ថភាពក្នុងការសងត្រឡប់មកវិញ បំពេញលក្ខខណ្ឌឱ្យបានគ្រប់គ្រាន់ និងទ្រព្យបញ្ចាំរបស់អតិថិជន។ម្យ៉ាងវិញទៀតធនាគារស្ថាបនា ភីអិលស៊ី ពិតជាមានវិធីសាស្ត្រនិងមានការការពារយ៉ាងរលូនក្នុងការជួបបញ្ហារវាងធនាគារ និងអតិថិជន ដើម្បីធ្វើឱ្យឥណទានមានភាពល្អប្រសើរជាងមុន។

ជាចុងបញ្ចប់នេះក្រុមនាងខ្ញុំ សូមធ្វើការអភ័យទោស និងអធ្យាស្រ័យអំពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រចារ្យ មិត្តអ្នកអាន និងអ្នកស្រាវជ្រាវទាំងអស់ចំពោះកំហុសខុសឆ្គងនៅក្នុងប្រការណាមួយ ដែលបានកើតឡើងដោយអចេតនា ព្រោះវាគ្រាន់តែការលើកយកមកបង្ហាញអំពីកិច្ចការស្រាវជ្រាវ ដែលទាក់ទងអំពីប្រធានបទ ការគ្រប់គ្រងហានិភ័យក្នុងផ្តល់ឥណទានរបស់ធនាគារស្ថាបនា ភីអិលស៊ី បន្ថែមលើមេរៀនដែលបានសិក្សាកន្លងមកតែប៉ុណ្ណោះ។ ថ្វីត្បិតតែកិច្ចការស្រាវជ្រាវនេះ មិនបានបង្ហាញពីទិន្នន័យគ្រប់ជ្រុងជ្រោយ យើងក៏ពិតមែន ប៉ុន្តែវាជាឯកសារដែលមានប្រយោជន៍ សម្រាប់និស្សិតជំនាន់ក្រោយដែលធ្វើជាគម្រូ និងការស្រាវជ្រាវដែលទាក់ទងជុំវិញប្រធានបទ ការគ្រប់គ្រងហានិភ័យក្នុងផ្តល់ឥណទានរបស់ធនាគារស្ថាបនាផងដែរ។ នាងខ្ញុំសូមទទួលការចូលរួមចំណែកកែលម្អដើម្បីស្ថាបនាដោយការយោគយល់ និងអនុគ្រោះដោយក្តីរីករាយ ។

## ៥.២ អនុសាសន៍

ឆ្លងតាមការសន្និដ្ឋានលើការស្រាវជ្រាវទាក់ទងនឹងប្រធានបទខាងលើរួចមក យើងសង្កេតឃើញថា ធនាគារមានចំណុចខ្លាំងជាច្រើនក្នុងការគ្រប់គ្រង តែក៏នៅមានចំណុចខ្វះខាតមួយចំនួនតូចផងដែរ ដែលគួរតែធ្វើការកែលម្អឱ្យបានកាន់តែប្រសើរឡើងក្នុងការគ្រប់គ្រងហានិភ័យឥណទាន មានដូចខាងក្រោម៖

- ធនាគារគួរពន្យាពេលនៃការផាកពិន័យចំពោះការបង់ប្រាក់យឺតយ៉ាវ របស់អតិថិជនតាមដែលអាចធ្វើទៅបាន ដោយអាស្រ័យទៅលើបរិបទណាមួយដែលជះឥទ្ធិពលដល់សេដ្ឋកិច្ចជាតិទាំងមូល។
- ទៅលើការផ្សព្វផ្សាយសេវារបស់ធនាគារ ហាក់បីដូចជានៅមានកម្រិត ដូច្នេះធនាគារគួរតែធ្វើការផ្សព្វផ្សាយឱ្យបានច្រើននិងទូលំទូលាយជាងមុនដើម្បីឱ្យប្រជាពលរដ្ឋយល់ដឹងកាន់តែច្រើន។
- មុននឹងផ្តល់កម្ចីឱ្យអតិថិជនគួរតែសិក្សាពីគោលបំណងរបស់អតិថិជន ឱ្យបានច្បាស់លាស់ថាអតិថិជនគាត់យកកម្ចីទៅធ្វើអ្វី ឬបំពេញតម្រូវការត្រឹមត្រូវដែរឬទេ។

# ឯកសារយោង

# ឯកសារយោង

ឯកសារទាំងនេះបានមក តាមរយៈឯកសារមួយចំនួនដូចខាងក្រោម៖


1. https://khemsarith.wordpress.com 24/02/2024
2. https://m.facebook.com/permalink.php 24/02/2024
3. https://images.app.goo.gl/U6xaCXTUXYsWwJYQA 24/02/2024
4. https://en.m.wikipedia.org/wiki/History_of_banking 24/02/2024
5. https://www.facebook.com 24/02/2024
6. https://m.tnaot.com/km/m/detail/article/2127308 24/02/2024
7. «ច្បាប់, នីតិ និងវិន័យ» តើមានលក្ខណៈខុសគ្នាដូចម្តេច ? (thmeythmey.com) (24/02/24)
8. https://www.facebook.com/profile.php?id=100038469349584 24/02/2024
9. http://ocsrp.blogspot.com/2016/05/blog-post_78.html?m=1 24/02/2024
10. https://www.facebook.com/Khemsarithedu 24/02/2024
11. https://www.khsearch.com/qna/24819 24/02/24
12. https://clubniset.wordpress.com/ 24/02/24
13. https://www.facebook.com/ 24/02/24
14. https://fhsu.pressbooks.pub/management/chapter/the-history-of-management/ 24/02/2024
15. https://www.khsearch.com/qna 24/02/2024
16. https://www.sathapana.com.kh/kh/about-us 25/02/2024
17. https://www.nbc.gov.kh/ 25/02/2024

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

- **ការិយាល័យកណ្ដាលរបស់ធនាគារ ស្ថាបនា ភីអិលស៊ី**
    - ទីតាំងស្ថិតនៅមហាវិថីព្រះនរោត្តម កែងផ្លូវលេខ១៧២ និងផ្លូវលេខ១៧៤ ភូមិភូមិ១៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ



- **រចនាសម្ព័ន្ធរបស់ធនាគារ ស្ថាបនា ភីអិលស៊ី**



# អំពីធនាគារ ស្ថាបនា

ធនាគារ ស្ថាបនា ភីអិលស៊ី ជាធនាគារពាណិជ្ជឈានមុខគេមួយនៅកម្ពុជា ដែលមានបុគ្គលិកសម្បូរទៅដោយទេពកោសល្យ និងប្រកបដោយវិជ្ជាជីវៈប្រមាណជាង ៤.០០០ នាក់ និងទ្រព្យសកម្មសរុបប្រមាណជាង ២,៧ ពាន់លានដុល្លារអាមេរិក។ ក្នុងនោះផងដែរ យើងមានសាខាធនាគារ ស្ថាបនា គ្រប់គ្រង ចំនួន បណ្តាញសាខាទូទាំងប្រទេសច្រើនជាង ១៧២ និងម៉ាស៊ីនអេធីអឹម ច្រើនជាង ២៩៥ ។ ដូច្នេះមិនថាលោកអ្នកនៅទីណានោះទេ ធនាគារ ស្ថាបនា នៅក្បែរលោកអ្នកជានិច្ច។

ដើម្បីផ្តល់នូវភាពងាយស្រួល និងធ្វើឱ្យជីវិតរបស់លោកអ្នកកាន់តែទាន់សម័យ យើងផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុ និងធនាគារយ៉ាងសម្បូរបែបឆ្លើយតបទៅតាមតម្រូវការលោកអ្នកដូចជា សេវាឥណទាន ប្រាក់បញ្ញើ iBanking ប័ណ្ណឥណពន្ធ និងប័ណ្ណឥណទាន សេវាផ្ទេរប្រាក់ក្នុងស្រុក និងក្រៅប្រទេស សេវាផ្ទេរប្រាក់តាមរយៈ Western Union ហិរញ្ញប្បទានពាណិជ្ជកម្ម និងសេវាកម្មជាច្រើនទៀត។ បន្ថែមពីលើនេះទៀត យើងក៏ផ្តល់ជូននូវសេវាប្រមូលពន្ធ និងទូទាត់ថ្លៃសេវាសាធារណៈជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ។

ធនាគារ ស្ថាបនា តែងតែស្វែងរកមធ្យោបាយថ្មីៗ ដើម្បីកែលម្អសេវាធនាគារឱ្យកាន់តែល្អប្រសើរ និងនាំមកជូននូវប្រតិបត្តិការធនាគារប្រចាំថ្ងៃកាន់តែងាយស្រួល យើងសហការជាមួយក្រុមហ៊ុនសេវាទូទាត់ប្រាក់ចល័តដូចជា៖ វីង ដាយ តេ ទ្រូម៉ាន់នី លី ហ្ស៊ូ បេរ៉ុយ អ៊ី-ម៉ាន់នី និងបាគង ជាដើម។

កម្មវិធីស្ថាបនា មុំបាល របស់យើងត្រូវបានទទួលស្គាល់ថាជា "កម្មវិធីធនាគារចល័តល្អបំផុតប្រចាំឆ្នាំ ២០២២" ពីទស្សនាវដ្តី Global Brands នៅចក្រភពអង់គ្លេស និង "កម្មវិធីធនាគារចល័តឆ្នើម និង ការច្នៃប្រឌិតប្រព័ន្ធទូទាត់ប្រចាំឆ្នាំ" ពី Asian Banking & Finance Retail Banking Awards។ ពានរង្វាន់ទាំងពីរនេះគឺ ជាសក្ខីភាពបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តរបស់យើង ដើម្បីបម្រើអតិថិជនរបស់យើងជាមួយនឹងការផ្តល់ជូននូវសេវាកម្ម និងបទពិសោធន៍ឌីជីថលដ៏ល្អបំផុត។

| ទ្រព្យសកម្ម | ឥណទានអតិថិជន |
|---|---|
| ២,៧៧ ពាន់លានដុល្លារអាមេរិក | ២,១១ ពាន់លានដុល្លារអាមេរិក |
| **ប្រាក់បញ្ញើអតិថិជន** | **ប្រាក់ចំណេញសរុប** |
| ១,៧៥ ពាន់លានដុល្លារអាមេរិក | ២១ លានដុល្លារអាមេរិក |
| **បណ្តាញសាខា** | **បុគ្គលិក** |
| ១៧២ | ៤.០០០+ |





## ចក្ខុវិស័យ

ជាធនាគារដែលឈានមុខគេ
និងជាទីទុកចិត្តបំផុតក្នុងការផ្តល់សេវាកម្មធនាគារ
ពេញលេញទូទាំងព្រះរាជាណាចក្រកម្ពុជា។

## បេសកកម្ម

ជួយលើកកម្ពស់អាជីវកម្ម និងការរស់នៅរបស់ប្រជាជនតាមរយៈការផ្តល់សេវាកម្មធនាគារពេញលេញជាមួយនឹងបច្ចេកវិទ្យាទាន់សម័យទូទាំងប្រទេស និងរួមចំណែកដល់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃព្រះរាជាណាចក្រកម្ពុជា។





# គុណតម្លៃ

**S – សេវាកម្មល្អឥតខ្ចោះ**

ជាធនាគារដែលទទួលបានការជឿទុកចិត្តតាមរយៈការប្តេជ្ញាចិត្តក្នុងការផ្តល់នូវសេវាកម្មដ៏ល្អបំផុតប្រកបដោយទំនួលខុសត្រូវ និងសុចរិតភាព។

**P – ធនធានជាចម្បង**

យើងយកចិត្តទុកដាក់ចំពោះគ្នា គោរពគ្នា និងជួយគ្នាទៅវិញទៅមកប្រកបដោយសាមគ្គីភាព។

**N – គំនិតថ្មី**

ស្វាគមន៍គំនិតច្នៃប្រឌិតថ្មី និងការស្វែងរកការកែលម្អជាបន្តបន្ទាប់ ដើម្បីឆាប់យកឱកាសអាជីវកម្មថ្មី។

**B – ការកសាងនិរន្តរភាព**

យើងប្តេជ្ញាចាក់ឫសគល់ក្នុងការគាំទ្រ និងជម្រុញការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់ធនាគារ និងសង្គមរបស់យើង។





# បណ្តាញសាខារបស់យើង

១៧២ សាខា

២៩៥ អេធីអឹម

២៥ ខេត្ត/ក្រុង

១.៦៧៤ ឃុំ/សង្កាត់

១៩៧ ស្រុក/ខណ្ឌ

១១.៤០៣ ភូមិ

៣០.០០០+ ភ្នាក់ងារសរុប

iBanking

សេវាធនាគារតាមទូរសព្ទ

ទំនាក់ទំនងសេវាកម្ម ២៤/៧



សាខាថ្មីបំផុតនៅផ្សារតំបន់ថ្មីជាមួយនឹងរូបរាងថ្មី និងផ្តល់ជូន
សេវាធនាគារដ៏ល្អឥតខ្ចោះជូនអតិថិជន

## បរិច្ចាគជូនមន្ទីរពេទ្យកុមារអង្គរ (AHC)

ធនាគារ ស្ថាបនា បានរៀបចំកម្មវិធី SATHAPANA Cup 2022 ដើម្បីប្រមូលថវិកាទៅបរិច្ចាគជូនមន្ទីរពេទ្យកុមារអង្គរ (AHC) ចំនួនទឹកប្រាក់សរុបចំនួន ៣.០០០ ដុល្លារអាមេរិកក្នុងការចូលរួមចំណែកការងារមនុស្សធម៌របស់មន្ទីរពេទ្យកុមារអង្គរ និងជួយកុមារកម្ពុជាទាំងអស់បន្តទទួលបានការព្យាបាលជំងឺមហារីក។ ធនាគារ ស្ថាបនា មានកិត្តិយសយ៉ាងខ្លាំងដែលបានចូលរួមជាផ្នែកមួយនៃកម្មវិធីសប្បុរធម៌នេះ ក្នុងការចូលរួមសម្មភាពសង្គម ជាពិសេសជួយដល់កុមារដែលត្រូវការជំនួយបំផុត។



## បរិច្ចាគថវិកាជូនដល់មូលនិធិរក្សាកុមារ

